ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍បូកសរុបលទ្ធផលការងារ
# គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
# ប្រចាំឆ្នាំ២០២៤ និងទិសដៅអនុវត្តឆ្នាំ២០២៥

ខែ កុម្ភៈ ឆ្នាំ ២០២៥

# មាតិកា


១. សេចក្តីផ្តើម ...... ១

២. បេសកកម្ម និងភារកិច្ច របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ...... ១

៣. ផែនការយុទ្ធសាស្ត្រគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និង គណៈកម្មការទន្លេមេគង្គ ...... ២

៣.១ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ...... ២

៣.២ គណៈកម្មការទន្លេមេគង្គ (Mekong River Commission-MRC) ...... ៣

៤. វឌ្ឍនភាព និងសមិទ្ធផលសម្រេចបានក្នុងឆ្នាំ ២០២៤ ...... ៥

៤.១ លទ្ធផលការងារ ...... ៥

ក. ការគាំទ្រ និងការពិនិត្យតាមដានកិច្ចដំណើរការស្ថាប័ន ...... ៥

ខ. ការពង្រឹងកិច្ចសហប្រតិបត្តិការតំបន់ និងភាពជាដៃគូ ...... ៩

ខ.១. កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌ MRC ...... ៩

ខ.២. កិច្ចសហប្រតិបត្តិការក្រោមយន្តការកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងមេគង្គ និងដៃគូផ្សេងទៀត ...... ១៤

ខ.២.១. ក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ...... ១៤

ខ.២.២. ក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-កូរ៉េ ...... ១៥

ខ.២.៣. ក្របខណ្ឌកិច្ចសហប្រតិបត្តិការភាពជាដៃគូមេគង្គ-សហរដ្ឋអាមេរិក ...... ១៦

ខ.២.៤.ក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-គង្គា ...... ១៧

ខ.២.៧.ក្របខណ្ឌកិច្ចសហប្រតិបត្តិការជាមួយ IUCN ...... ១៨

ខ.២.៨.ក្របខណ្ឌកិច្ចសហប្រតិបត្តិការគម្រោងឆ្លងដែន ក្រោមការគាំទ្រមូលនិធិរបស់ GIZ ...... ១៨

ខ.២.៩.ក្របខណ្ឌកិច្ចសហប្រតិបត្តិការ ACMECS ...... ១៩

ខ.២.១០.ក្របខណ្ឌកិច្ចសហប្រតិបត្តិការកម្ពុជា-ឡាវ ...... ១៩

ខ.២.១១.ក្របខណ្ឌកិច្ចសហប្រតិបត្តិការកម្ពុជា-ថៃ ...... ១៩

ខ.២.១២.ក្របខណ្ឌកិច្ចសហប្រតិបត្តិការកម្ពុជា-វៀតណាម ...... ១៩

ខ.២.១៣.ក្របខណ្ឌកិច្ចសហការការងារជាមួយដៃគូពាក់ព័ន្ធផ្សេងទៀត ...... ២០

គ. ការពង្រឹងសមត្ថភាព និងការបណ្តុះបណ្តាល ...... ២២

ឃ. ការបញ្ជ្រាបយេនឌ័រ ក្នុងការគ្រប់គ្រងអាងទន្លេ និងធនធានទឹកចម្រុះ ...... ២៣

ង. ផលិតផលក្នុងឆ្នាំ ២០២៤ គាំទ្រដល់កិច្ចដំណើរការ ការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងអាងទន្លេមេគង្គ ...... ២៤

ច. ការសិក្សាស្រាវជ្រាវ និងការពង្រឹងលើការពិនិត្យតាមដានទន្លេ និងស្ថានភាពធនធានពាក់ព័ន្ធ ក្នុងអាងទន្លេមេគង្គ ........ ២៦

ឆ. ការលើកកម្ពស់ការយល់ដឹង និងការផ្សព្វផ្សាយ ........ ២៧

**៤.២ បញ្ហាប្រឈម** ........ ២៩

**៥. ការបូកសរុប និងសេចក្តីសន្និដ្ឋាន** ........ ៣០

**៦. ទិសដៅការងារឆ្នាំ ២០២៥** ........ ៣១

## ១. សេចក្តីផ្តើម

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (គ.ជ.ទ.ម.ក) ត្រូវបានបង្កើតឡើងតាមសេចក្តីសម្រេច លេខ៣១៩/៨០ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៨០ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។ សេចក្តីសម្រេចនេះ ត្រូវបានជំនួសដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩០៩/៩៤៣ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការកែសម្រួល និងការធ្វើនិយតភាពការបង្កើត គ.ជ.ទ.ម.ក ដែលបានចែងថាៈ គ.ជ.ទ.ម.ក **គឺជាស្ថាប័នជាតិមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាលសម្រាប់សម្របសម្រួលក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ។** ដើម្បីអនុវត្តបេសកកម្មជាយុទ្ធសាស្ត្រនេះ គ.ជ.ទ.ម.ក បានរៀបចំផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ របស់ខ្លួនជាបន្តបន្ទាប់ ដែលផែនការយុទ្ធសាស្ត្របច្ចុប្បន្នគឺឆ្នាំ ២០២៤-២០២៨ ដើម្បីរួមចំណែកគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ឆ្នាំ ២០២៤-២០២៨ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា និងដើម្បីបន្តចូលរួមអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ ឆ្នាំ ២០២១-២០៣០ របស់គណៈកម្មការទន្លេមេគង្គ (Mekong River Commission-MRC) ឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យនៅថ្នាក់ជាតិ "កិច្ចសហប្រតិបត្តិការកាន់តែរឹងមាំក្នុងក្របខណ្ឌ "ទន្លេមេគង្គតែមួយ ស្មារតីតែមួយ" ឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្នុងអាងទន្លេមេគង្គ" និងនៅថ្នាក់តំបន់ "អាងទន្លេមេគង្គ មានវិបុលភាពផ្នែកសេដ្ឋកិច្ច យុត្តិធម៌សង្គម បរិស្ថានល្អ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ"។

## ២. បេសកកម្ម និងភារកិច្ច របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

គ.ជ.ទ.ម.ក ជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានបេសកកម្ម សម្របសម្រួលក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និង ធនធានពាក់ព័ន្ធដទៃទៀត ក្នុងអាងទន្លេមេគង្គ ប្រកបដោយនិរន្តភាព។ គ.ជ.ទ.ម.ក មានមុខងារ និងភារកិច្ច ដូចខាងក្រោម៖

- ជាសេនាធិការ ជំនួយការឱ្យរាជរដ្ឋាភិបាលលើរាល់ការគ្រប់គ្រង ការពិនិត្យពិចារណា ការសិក្សា និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ ក្នុងក្របខណ្ឌទូទាំងប្រទេស ដើម្បីបុព្វហេតុសេដ្ឋកិច្ចជាតិ និងផលប្រយោជន៍របស់ប្រជាជន និងបុព្វហេតុសន្តិភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ធ្វើការសិក្សា ពិនិត្យពិចារណា ហើយលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យសម្រេចលើរាល់បញ្ហាទាំងឡាយណាដែលទាក់ទងនឹងការធ្វើផែនការ ការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រង ការថែរក្សាការពារ និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ ប្រកបដោយនិរន្តរភាព
- សម្របសម្រួល និងសហការអនុវត្តជាមួយក្រសួង-ស្ថាប័នជាតិ ក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ ប្រកបដោយនិរន្តរភាព
- រួមសហការជាមួយក្រសួង-ស្ថាប័ន រាជធានី-ខេត្តក្រុងពាក់ព័ន្ធ ដើម្បីអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់រាជរដ្ឋាភិបាល ស្តីពីអាងទន្លេមេគង្គ

- ពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយនឹងគណៈកម្មាធិការជាតិទន្លេមេគង្គ នៃបណ្តាប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ជាមួយបណ្តាដៃគូអភិវឌ្ឍន៍ និងអង្គការតំបន់និងអន្តរជាតិផ្សេងៗ ក្នុងការពិនិត្យពិចារណា ការសិក្សា ការអភិវឌ្ឍ ការគ្រប់គ្រង និងការថែរក្សាធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ ឱ្យបានសមស្របទៅនឹងផលប្រយោជន៍ដ៏សមរម្យរបស់បណ្តាប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ និងដោយត្រឹមត្រូវតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីអាងទន្លេមេគង្គ
- ធ្វើទំនាក់ទំនង សម្របសម្រួលជាមួយគណៈកម្មការទន្លេមេគង្គ និងដៃគូអភិវឌ្ឍន៍ដើម្បីស្វែងរកថវិកាជំរុញការសិក្សា និងការអភិវឌ្ឍគម្រោងឱ្យបានឆាប់រហ័សទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់
- គៀងគររកមធ្យោបាយ និងធនធានដើម្បីរួមចំណែកក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងវិស័យធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ
- អប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងដល់អ្នកពាក់ព័ន្ធ និង
- បំពេញភារកិច្ចផ្សេងទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## ៣. ផែនការយុទ្ធសាស្ត្រគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និង គណៈកម្មការទន្លេមេគង្គ

### ៣.១ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

ដោយរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ឆ្នាំ២០២៤-២០២៨ និងដើម្បីចូលរួមចំណែកគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ លើអាទិភាពការងារដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានទឹក និងអាងទន្លេឱ្យមានប្រសិទ្ធភាព និងដើម្បីគាំទ្រ និងពង្រឹងការចូលរួមរបស់កម្ពុជា សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងអាងទន្លេមេគង្គ ទាំងនៅជាតិ និងថ្នាក់តំបន់, គ.ជ.ទ.ម.ក បានធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្ររបស់ខ្លួន សម្រាប់ ឆ្នាំ២០២៤-២០២៨ ដោយក្នុងនោះ បានកំណត់នូវទិសដៅការងារជាអាទិភាពចំនួន ៥ រួមមាន៖ ទី១) ពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារឱ្យកាន់តែប្រសើរ, ទី២) គាំទ្រ និងពង្រឹងកិច្ចប្រតិបត្តិការការងារ និងការគ្រប់គ្រងធនធានទឹក និងអាងទន្លេប្រកបដោយប្រសិទ្ធភាពដោយមានការចូលរួម និងកិច្ចសហការ, ទី៣) ពង្រឹង លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូដើម្បីធានាបាននូវការអភិវឌ្ឍ និងការគ្រប់គ្រងអាងទន្លេ ប្រកបដោយចីរភាព, ទី៤) លើកកម្ពស់ការយល់ដឹងសាធារណៈ និងការផ្សព្វផ្សាយ ដើម្បីពង្រឹងការចូលរួម និងប្រើប្រាស់ផលិតផល MRC សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍតាមវិស័យ ដោយកិច្ចសហប្រតិបត្តិការ និងមានការចូលរួម និងទី៥) ពង្រឹងប្រសិទ្ធភាព នៃការពិនិត្យតាមដាន និងធ្វើឱ្យប្រសើរកិច្ចដំណើរការជាប្រចាំ។ ផែនការយុទ្ធសាស្ត្រ ត្រូវបានអនុវត្តតាមរយៈផែនការការងារប្រចាំឆ្នាំរបស់ គ.ជ.ទ.ម.ក ដែលសម្របសម្រួលអនុវត្តដោយអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក និងដោយមានការចូលរួម កិច្ចសហការ និងការគាំទ្រពីក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធផ្សេងទៀត ។

ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ គ.ជ.ទ.ម.ក ធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នជាសមាជិកលេខាធិការដ្ឋាន MRC និងជាមួយបណ្តាគណៈកម្មាធិការជាតិទន្លេមេគង្គនៃប្រទេសជាសមាជិកផ្សេងទៀត រួមមានឡាវ ថៃ និងវៀតណាម ក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយជោគជ័យនូវកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ និងបណ្តានីតិវិធី

ស្ដីពីគ្រប់គ្រងការប្រើប្រាស់ទឹករបស់ MRC និងក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ យុទ្ធសាស្ត្រអភិវឌ្ឍន៍អាង ដោយផ្អែកលើគោលការណ៍នៃការគ្រប់គ្រងធនធានទឹកចម្រុះ ការងារវិមជ្ឈការមុខងារស្នូលនៃការគ្រប់គ្រងអាងទន្លេ និងបណ្ដាគម្រោងនិងកម្មវិធីកិច្ចសហប្រតិបត្តិការតំបន់ ទន្លេឆ្លងដែន សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងអាងទន្លេមេគង្គ ។




### ៣.២ គណៈកម្មការទន្លេមេគង្គ (Mekong River Commission-MRC)

MRC គឺជាស្ថាប័នអន្តររដ្ឋាភិបាល ត្រូវបានបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀង ស្ដីពីកិច្ចសហប្រតិបត្តិការ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេមេគង្គ ដែលបានចុះហត្ថលេខានាថ្ងៃទី៥ ខែមេសា ឆ្នាំ ១៩៩៥ ដោយប្រទេសជាសមាជិករួមមាន៖ កម្ពុជា ឡាវ ថៃ និងវៀតណាម។

MRC មានបេសកកម្ម ក្នុងការសម្របសម្រួល និងលើកកម្ពស់កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ នៃការអភិវឌ្ឍ ការប្រើប្រាស់ ការគ្រប់គ្រង និងការអភិរក្សប្រកបដោយចីរភាពនៃធនធានទឹក និងធនធានពាក់ព័ន្ធ ក្នុងអាងទន្លេមេគង្គ រួមមាន ការស្រោចស្រព វារីអគ្គិសនី នាវាចរណ៍ ការត្រួតពិនិត្យទឹកជំនន់ ជលផលជាដើម ក្នុងលក្ខណៈមួយដើម្បីធ្វើឱ្យការប្រើប្រាស់ពហុបំណង បានកាន់តែប្រសើរឡើង និងផ្ដល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកក្នុងចំណោមបណ្ដាប្រទេសតាមដងទន្លេមេគង្គ និងដើម្បីកាត់បន្ថយផលប៉ះពាល់អាក្រក់ដែលអាចកើតឡើងពីបាតុភូតធម្មជាតិ និងពីសកម្មភាពរបស់មនុស្ស។ ដើម្បីអនុវត្តបេសកកម្មរបស់ខ្លួន, MRC បានរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍អាង និងផែនការយុទ្ធសាស្ត្រ និងបានធ្វើបច្ចុប្បន្នភាពតាមដំណាក់កាល

ជាបន្តបន្ទាប់ ដោយបច្ចុប្បន្ន MRC បាននិងកំពុងអនុវត្តយុទ្ធសាស្រ្តអភិវឌ្ឍន៍អាង ឆ្នាំ២០២១-២០៣០ និងផែនការយុទ្ធសាស្រ្ត ឆ្នាំ ២០២១-២០២៥។ ផែនការយុទ្ធសាស្រ្ត ឆ្នាំ២០២១-២០២៥ បានកំណត់នូវកម្មវិធីការងារជាអាទិភាព ដែល MRC ត្រូវអនុវត្តដើម្បីជំរុញកិច្ចសហប្រតិបត្តិការតំបន់ក្នុងចំណោមប្រទេសជាសមាជិក ជាមួយប្រទេសដៃគូសន្ទនា (ចិន និងមីយ៉ាន់ម៉ា) ដៃគូអភិវឌ្ឍន៍ អង្គការតំបន់និងអន្តរជាតិ និងភាគីពាក់ព័ន្ធផ្សេងទៀត សំដៅសម្រេចឱ្យបាននូវការអភិវឌ្ឍ ការប្រើប្រាស់ ការគ្រប់គ្រង និងការអភិរក្សធនធានទឹក និងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ ប្រកបដោយចីរភាព ស្របតាមគោលបំណងដែលមានចែងក្នុងកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥។ យុទ្ធសាស្រ្តអភិវឌ្ឍន៍អាង និងផែនការយុទ្ធសាស្រ្ត របស់ MRC បានកំណត់នូវអាទិភាពជាយុទ្ធសាស្រ្តចំនួន ៥ ផ្តោតលើផ្នែកៈ (ទី១) ផ្នែកបរិស្ថានៈ ថែរក្សាមុខងារអេកូឡូស៊ីនៃអាងទន្លេមេគង្គ (ទី២) ផ្នែកសង្គមៈ ផ្តល់លទ្ធភាពដែលអាចប្រើប្រាស់ទឹក និងធនធានពាក់ព័ន្ធនៃអាងទន្លេមេគង្គប្រកបដោយបរិយាបន្ន (ទី៣) ផ្នែកសេដ្ឋកិច្ចៈ លើកកម្ពស់ការអភិវឌ្ឍវិស័យធនធានទឹក និងវិស័យពាក់ព័ន្ធ ឱ្យមានលក្ខណៈប្រសើរបំផុត និងប្រកបដោយចីរភាព, (ទី៤) ផ្នែកការប្រែប្រួលអាកាសធាតុៈ ពង្រឹងភាពធន់ទប់ទល់នឹងហានិភ័យនៃអាកាសធាតុ,គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតធ្ងន់ធ្ងរ និង (ទី៥) ផ្នែកកិច្ចសហប្រតិបត្តិការៈ ពង្រឹងកិច្ចសហប្រតិបត្តការក្នុងចំណោមប្រទេសក្នុងអាងទន្លេមេគង្គទាំងអស់ និងអ្នកពាក់ព័ន្ធនានា ។



នៅក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការ MRC, ប្រទេសជាសមាជិកនីមួយៗ មានគណៈកម្មាធិការជាតិទន្លេមេគង្គ (National Mekong Committee-NMC) របស់ខ្លួន ដែលនៅកម្ពុជា គឺគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (Cambodia National Mekong Committee-CNMC) ដែលមានតួនាទី ក្នុងការសម្របសម្រួលនៅថ្នាក់ជាតិ និងក្របខណ្ឌតំបន់ លើការរៀបចំ ការអនុវត្ត ការពិនិត្យតាមដាន ការវាយតម្លៃលើផែនការ យុទ្ធសាស្ត្រ គម្រោង កម្មវិធី និងសកម្មភាពការងារនានារបស់ MRC។

រចនាសម្ព័ន្ធ និងយន្តការសម្របសម្រួលការងារ






## ៤. ឧត្តមភាព និងសមិទ្ធផលសម្រេចបានក្នុងឆ្នាំ ២០២៤

ក្នុងនាមជាស្ថាប័នថ្នាក់ជាតិ មានបេសកកម្មសម្របសម្រួលក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍ ធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀតក្នុងអាងទន្លេមេគង្គ និងធ្វើកិច្ចសហប្រតិបត្តិការដើម្បីការអភិវឌ្ឍប្រកប ដោយចីរភាពក្នុងអាងទន្លេមេគង្គ, គ.ជ.ទ.ម.ក បានបំពេញការងារដោយផ្អែកលើផែនការងារឆ្នាំ២០២៤, សម្រេចបានលទ្ធផលដែលមានខ្លឹមសារសង្ខេប ដូចខាងក្រោម៖

### ៤.១ លទ្ធផលការងារ

#### ក. ការគាំទ្រ និងការពិនិត្យតាមដានកិច្ចដំណើរការស្ថាប័ន

- បានដាក់ចេញ និងផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ និងផែនការសកម្មភាពឆ្នាំ ២០២៤ របស់ គ.ជ.ទ.ម.ក
- បានពង្រឹង លើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តការងាររបស់អគ្គលេខាធិការដ្ឋាន ដែលជាសេនាធិការក្នុងការដឹកនាំសម្របសម្រួលការអនុវត្តការងារជារួមរបស់ គ.ជ.ទ.ម.ក ដោយបាន ផ្តោតជាសំខាន់លើ ការពិនិត្យតាមដានការអនុវត្តផែនការការងារប្រចាំឆ្នាំ២០២៤ របស់ គ.ជ.ទ.ម.ក, ការពង្រឹងកិច្ចសហការ ការប្រាស្រ័យទាក់ទងនិងកិច្ចសម្របសម្រួល ការលើកកម្ពស់ការពិគ្រោះយោបល់ ការពង្រឹងសមត្ថភាពជំនាញ ការផ្សព្វផ្សាយ និងការលើកកម្ពស់ការយល់ដឹងជាដើម




- ជាផ្នែកមួយនៃការពង្រឹង និងការកែទម្រង់ស្ថាប័ន ដើម្បីប្រសិទ្ធភាពការងារ និងផ្នែកអភិបាលកិច្ច ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា គ.ជ.ទ.ម.ក បាន៖
    - √ ពិនិត្យឡើងវិញ និងធ្វើការវិភាគមុខងារ និងរចនាសម្ព័ន្ធរបស់ គ.ជ.ទ.ម.ក ដោយបានពិភាក្សាផ្ដៃក្នុងកំណត់មុខងារគោល រួមមានមុខងារស្នូល និងមុខងារជំនាញ
    - √ លើកសំណើជូនរាជរដ្ឋាភិបាល និងបានទទួលការសម្រេចឯកភាពជាគោលការណ៍លើការផ្ទេររចនាសម្ព័ន្ធគ្រប់គ្រងថបនីយជីវមណ្ឌលបឹងទន្លេសាប (លេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប និងលេខាធិការ) ដែលបច្ចុប្បន្នជាអង្គភាពមួយ ស្ថិតនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ គ.ជ.ទ.ម.ក ទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់អាជ្ញាធរទន្លេសាប។ បច្ចុប្បន្ន អាជ្ញាធរទន្លេសាបបាន និងកំពុងពិនិត្យកែទម្រង់ស្ថាប័ន ដាក់បញ្ចូលលេខាធិការដ្ឋានថបនីយជីវមណ្ឌលបឹងទន្លេសាប នៅក្នុងរចនាសម្ព័ន្ធរបស់ខ្លួន
    - √ រៀបចំសេចក្តីព្រាង៖ ទី១)អនុក្រឹត្យ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៩៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក និង ទី២) ប្រកាស ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅរបស់បណ្តានាយកដ្ឋាន ក្រោមឱវាទអគ្គលេខាធិការដ្ឋានគ.ជ.ទ.ម.ក ។








- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា សរុប ៥១រូបនិងបានលើកសំណើអំពីតម្រូវការឧបករណ៍សម្ភារៈ ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងវត្តមាន និងស្ថានភាពមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា
- ពិនិត្យវឌ្ឍនភាពការងារ នៃការអនុវត្តផែនការការងារក្នុងឆ្នាំ ២០២៤ ជាប្រចាំតាមរយៈកិច្ចប្រជុំប្រចាំខែ ត្រីមាស ឆមាស និងរបាយការណ៍ និងការរៀបចំផែនការសកម្មភាព ឆ្នាំ២០២៥
- បានដំណើរការរៀបចំកិច្ចប្រជុំសមាសភាព គ.ជ.ទ.ម.ក ឆ្នាំ២០២៤ លើកដំបូងក្នុងអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ស្តីពីកិច្ចសហប្រតិបត្តិការ និងសមិទ្ធផលការងារក្នុងក្របខណ្ឌ MRC ក្នុងការគ្រប់គ្រង ការប្រើប្រាស់ ការអភិវឌ្ឍ និងការអភិរក្សធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀត ក្នុងអាងទន្លេមេគង្គ
- បានចូលរួមសហការ ក្នុងការរៀបចំប្រកបដោយជោគជ័យ សន្និបាតបូកសរុបលទ្ធផលការងារក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា អាជ្ញាធរទន្លេសាប ឆ្នាំ២០២៣ និងទិសដៅអនុវត្ត ឆ្នាំ២០២៤







- បានផ្តល់សេចក្តីសង្ខេប ស្តីពីសមិទ្ធផលការងាររបស់ គ.ជ.ទ.ម.ក ក្នុងឆ្នាំទី១ នៃអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ជាផ្នែកមួយនៃរបាយការណ៍រួមរបស់ក្រសួងធនធានទឹក និងឧតុនិយម រាយការណ៍ជូនរាជរដ្ឋាភិបាល
- បានផ្តល់ធាតុចូល សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ឆ្នាំ ២០២៤-២០២៨ និងសម្រាប់របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិ ដោយស្ម័គ្រចិត្តឆ្នាំ ២០២៤ នៃការសម្រេចបានគោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា ឆ្នាំ ២០១៦-២០៣០
- បានពង្រឹងទំនាក់ទំនង និងកិច្ចសហការការងារក្នុងក្របខណ្ឌជាតិ ដោយបានលើកកម្ពស់ការពិគ្រោះយោបល់ និងការចូលរួមតាមវិស័យលើផ្នែកធនធានទឹក ការគ្រប់គ្រងទឹកជំនន់ ភាពរាំងស្ងួត ការប្រែប្រួលអាកាសធាតុ ជលផល បរិស្ថាន កសិកម្ម នាវាចរណ៍ និងផ្នែកយេនឌ័រជាដើម បានកាន់តែទូលំទូលាយ។ ព្រឹត្តិការណ៍ថ្នាក់ជាតិ ជាសិក្ខាសាលា កិច្ចប្រជុំវេទិកា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សា ដែល គ.ជ.ទ.ម.ក បានរៀបចំ និងមាន




មន្ត្រីនៃក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធនានាបានចូលរួម គឺមានចំនួន ១៥៩ ព្រឹត្តិការណ៍

- បានពង្រឹងទំនាក់ទំនង និងកិច្ចសហការការងារក្នុងកម្រិតតំបន់ ដោយបានលើកកម្ពស់ការចូលរួមរបស់កម្ពុជា ក្នុងការពិគ្រោះយោបល់តាមវិស័យ និងផ្នែកក្នុងក្របខណ្ឌការងារ MRC ឈរលើស្មារតីមេគង្គ ក្នុងការអនុវត្ត ការធ្វើបច្ចុប្បន្នភាព ការរៀបចំផែនការគម្រោង ព្រមទាំងគោលការណ៍និងឧបករណ៍បច្ចេកទេសសម្រាប់គាំទ្រ និងមប្រើដល់ការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងដោយចីរភាព លើផ្នែកធនធានទឹក ការគ្រប់គ្រងទឹកជំនន់ ភាពរាំងស្ងួត ការប្រែប្រួលអាកាសធាតុ ជលផល បរិស្ថាន កសិកម្ម នាវាចរណ៍ និងផ្នែកយេនឌ័រជាដើម ក៏ដូចជាដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចដំណើរលេខាធិការដ្ឋាន MRC និងកិច្ចសម្របការងាររវាងថ្នាក់ជាតិ និងថ្នាក់តំបន់។ ព្រឹត្តិការណ៍ថ្នាក់តំបន់ជាសិក្ខាសាលា កិច្ចប្រជុំ វេទិកា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សា ដែលមានមន្ត្រីកម្ពុជា ពីក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធផ្សេងទៀត បានចូលរួម គឺមានចំនួន ១២៧ ព្រឹត្តិការណ៍




- ជំនាញការជាតិចំនួន ១១ រូប ត្រូវបានជ្រើសរើស ដើម្បីជួយដល់កិច្ចការតំបន់លើផ្នែកៈ ការគ្រប់គ្រងទីជម្រាល ការរៀបចំគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រង និងប្រើប្រាស់ទឹកក្រោមដោយចីរភាពសម្រាប់ផ្នែកកសិកម្ម ការរៀបចំផែនការបុរេសកម្មថ្នាក់តំបន់ ការអនុវត្តផែនការចង្អុលទិសថ្នាក់ជាតិ ការវាយតម្លៃផ្នែកយេនឌ័រ និងភាពងាយរងគ្រោះ ការរៀបចំសៀវភៅសុវត្ថិភាពសម្រាប់ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ក្នុងអាងទន្លេមេគង្គក្រោម ការសិក្សារួមគ្នាស្តីពីបម្រែបម្រួលផ្នែកជលផលក្នុងអាងទន្លេមេគង្គ-ឡានឆាង ការរៀបចំប្រព័ន្ធព័ត៌មានថ្នាក់ជាតិជាដើម ។

## ខ. ការពង្រឹងកិច្ចសហប្រតិបត្តិការតំបន់ និងភាពជាដៃគូ

ក្នុងកិច្ចខិតខំប្រឹងប្រែងពង្រឹងកិច្ចសហប្រតិបត្តិការ ក្នុងក្របខណ្ឌជាតិ ទ្វេភាគី តំបន់ និងអន្តរជាតិ និងភាពជាដៃគូផ្សេងទៀត ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈម លើកកម្ពស់ការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងអាងទន្លេ ដោយបំពេញបានតាមតម្រូវការ និងរក្សាបាននូវតុល្យភាព គ.ជ.ទ.ម.ក បានអនុវត្តកិច្ចការ និងសម្រេចបានលទ្ធផលការងារសំខាន់ៗ ដូចមានខ្លឹមសារសង្ខេបខាងក្រោម៖

### ខ.១. កិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌ MRC

- **ក្នុងចំណោមប្រទេសជាសមាជិក**

√ សមាជិកក្រុមប្រឹក្សា MRC តំណាងកម្ពុជា គឺ **ឯកឧត្តម ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធាន គ.ជ.ទ.ម.ក រួមនឹងសមាជិកក្រុមប្រឹក្សា MRC តំណាងប្រទេសជាសមាជិកផ្សេងទៀត បានជួបប្រជុំក្នុងកិច្ចប្រជុំក្រុមប្រឹក្សា MRC ប្រចាំឆ្នាំលើកទី៣១ នៅចុងខែវិច្ឆិកា ឆ្នាំ២០២៤ នៅឡាវជាប្រទេសម្ចាស់ផ្ទះក្នុងនាមជាប្រធានក្រុមប្រឹក្សា MRC សម្រាប់ឆ្នាំ២០២៤ ដើម្បីរួមគ្នាពិនិត្យឡើងវិញនូវ កិច្ចខិតខំប្រឹងប្រែង និងវឌ្ឍនភាពការងាររបស់ MRC ក្នុងឆ្នាំ២០២៤ និងដើម្បីបន្តធ្វើការផ្លាស់ប្តូរទស្សនៈគ្នា ស្តីពីកិច្ចសហប្រតិបត្តិការតំបន់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងអាងទន្លេមេគង្គ







√ ការរួមគ្នាពិនិត្យឡើងវិញនូវកិច្ចខិតខំប្រឹងប្រែង និងវឌ្ឍនភាពការងាររបស់ MRC ក្នុងឆ្នាំ២០២៤ ក៏ត្រូវបានពិនិត្យតាមដានដោយកម្ពុជា រួមសហការជាមួយប្រទេសជាសមាជិកផ្សេងទៀត ក្នុងក្របខណ្ឌយន្តការគណៈកម្មាធិការរួម MRC តាមរយៈកិច្ចប្រជុំប្រចាំឆ្នាំដែលបានរៀបចំធ្វើចំនួន ២លើក គឺគណៈកម្មាធិការរួម MRC លើកទី៥៧ និងលើកទី៥៨



√ កម្ពុជា និងប្រទេសជាសមាជិកផ្សេងទៀត បាន៖

- ចូលរួមក្នុងដំណើរការជ្រើសរើសនាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC ដោយបាន

ផ្តល់ការឯកភាពសម្រេចតែងតាំងលោកស្រី Busadee Santipitaks ជនជាតិថៃ ជានាយកប្រតិបត្តិនៃលេខាធិការដ្ឋាន MRC សម្រាប់អាណត្តិការងាររយៈពេល ៣ឆ្នាំ (២០២៥-២០២៧) ដែលនឹងចាប់ផ្តើមការងារពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៥ តទៅ

- រួមសហការគ្នាបន្តពង្រឹងប្រសិទ្ធភាពនៃកិច្ចដំណើរការក្របខណ្ឌស្ថាប័ន MRC និងការគ្រប់គ្រងអាងទន្លេ និងធនធានក្នុងអាង ដោយបានផ្តល់ការគាំទ្រ ការអនុម័ត ឯកភាពលើសំណើ ផែនការ និងការបញ្ចប់ការរៀបចំឯកសារការងារសំខាន់ៗមួយចំនួនរបស់ MRC ដែលរួមមានជាអាទិ៍៖
    - ការបន្តផ្តល់ការគាំទ្រកិច្ចសហប្រតិបត្តិការតំបន់ ដោយកម្ពុជា បានបង់វិភាគទានប្រចាំឆ្នាំ ២០២៤ បានទាន់ពេលវេលាជូន MRC តាមការសម្រេចឯកភាពរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈសជណ លេខ ១៣០៧ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាលកម្ពុជា
    - ផែនការការងារពហុឆ្នាំ ២០២៥-២០២៦ របស់ MRC
    - ឯកសារទស្សនទានអំពីពេលវេលាសម្រាប់រៀបចំកិច្ចប្រជុំកំពូល MRC
    - ការធ្វើបច្ចុប្បន្នភាពបន្ថែម សៀវភៅណែនាំផ្នែកលទ្ធកម្ម, ផ្នែកធនធានមនុស្ស និងផ្នែករដ្ឋបាលរបស់ MRC ដើម្បីពង្រឹងបន្ថែមដល់កិច្ចដំណើរការ និងការគ្រប់គ្រងនៅលេខាធិការដ្ឋាន MRC
    - ការធ្វើបច្ចុប្បន្នភាពវិធានផ្ទៃក្នុងរបស់គណៈកម្មាធិការសវនកម្ម MRC
    - ការធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំបច្ចេកទេស ដើម្បីអនុវត្តនីតិវិធីស្តីពីការជូនដំណឹងការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង
    - ការធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំបច្ចេកទេស ស្តីពីភាពទុកដាក់ទិន្នន័យ និងការគ្រប់គ្រងប្រព័ន្ធព័ត៌មាន MRC
    - ការរៀបចំគោលការណ៍បន្សាំនឹងភាពរាំងស្ងួត និងការធ្វើឱ្យប្រសើរឡើងនូវមជ្ឈមណ្ឌលគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួតថ្នាក់តំបន់
    - ការរៀបចំគោលការណ៍បច្ចេកទេស ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ទឹកក្រោមដីប្រកបដោយចីរភាព សម្រាប់វិស័យកសិកម្ម
    - លក្ខន្តិកៈការងារ នៃក្រុមជំនាញការរួម MRC-LMC ផ្នែកទិន្នន័យ ម៉ូដែល និងការព្យាករ
    - ការសាកល្បងប្រើប្រាស់មូលនិធិមេគង្គ សម្រាប់ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់មេគង្គ
    - ការរៀបចំអនុវត្តគម្រោងធ្វើឱ្យប្រសើរការគ្រប់គ្រងជលផលឆ្លងដែន ក្នុងអាងទន្លេមេគង្គក្រោម ដែលគាំទ្រដោយមូលនិធិបរិស្ថានសកល
    - ការបញ្ចប់គម្រោងគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួតក្នុងអាងទន្លេមេគង្គក្រោម និងការរៀបចំបន្តសម្រាប់ដំណាក់កាលទី៣
    - យន្តការនៃការចែករំលែកព័ត៌មាន និងទិន្នន័យ សម្រាប់ប្រតិបត្តិការទំនប់វារីអគ្គិសនី

ចំនួន ១៣ ក្នុងអាងទន្លេមេគង្គក្នុងចំណោមប្រទេសជាសមាជិក ដោយក្នុងនោះ នៅកម្ពុជាមាន ១ គម្រោង គឺទំនប់វារីអគ្គិសនីសេសានក្រោម ២

◦ របាយការណ៍ពីការរៀបចំផែនការបុរេសកម្មតំបន់ រួមទាំងការធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌគាំទ្រការធ្វើសេចក្តីសម្រេចចិត្ត

◦ របាយការណ៍នៃការបញ្ចប់លើការសាកល្បងអនុវត្តដោយស្ម័គ្រចិត្តនូវគោលការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនសម្រាប់គម្រោងទំនប់វារីអគ្គិសនីសេកុង A របស់ឡាវ

√ ដោយអាងទន្លេមេគង្គភាគខាងក្រោមក្នុងរដូវវស្សាឆ្នាំ២០២៤ នៅដើមខែកញ្ញា បានទទួលរងឥទ្ធិពលព្យុះទីហ្វុង Yagi បង្កឱ្យមានទឹកជំនន់ក្នុងបណ្តាប្រទេសតាមដងមេគង្គ ជាពិសេសនៅក្នុងប្រទេសឡាវ ថៃ និងវៀតណាម, **ឯកឧត្តម ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធាន គ.ជ.ទ.ម.ក ក្នុងនាមតំណាងកម្ពុជា បានធ្វើលិខិតផ្លូវការជូនទៅសមាភាគីនៃប្រទេសជាសមាជិកផ្សេងទៀត ចូលរួមរំលែកទុក្ខប្រកបដោយសមានចិត្តដ៏ជ្រាលជ្រៅបំផុត និងចំពោះការ បាត់បង់ជីវិតជាច្រើន និងបានធ្វើឱ្យប៉ះពាល់ និងបំផ្លិចបំផ្លាញធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិប្រជាជន សង្គម និងហេដ្ឋារចនាសម្ព័ន្ធ ដែលបានជួបប្រទះដោយសារតែព្យុះទីហ្វុង Yagi ។ នេះ បានបង្ហាញអំពីការយកចិត្តទុកដាក់ និងជាកាយវិការប្រកបដោយកិច្ចសហការរបស់កម្ពុជា ក្នុងគ្រាដែលប្រទេសជាសមាជិក ជួបការលំបាកដោយគ្រោះទឹកជំនន់មេគង្គ។


Kingdom of Cambodia
Nation Religion King
Cambodia National Mekong Committee

Lao National Mekong Committee

√ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការតំបន់ និងប្រសិទ្ធភាពនៃការធ្វើការរួមគ្នាក្នុងចំណោមប្រទេសជាសមាជិក, លេខាធិការដ្ឋាន MRC ក៏បានរៀបចំដំណើរទស្សនកិច្ចសិក្សាសម្រាប់ប្រទេសជាសមាជិក ទៅកាន់៖ (ទី១) ទីតាំងគម្រោងវារីអគ្គិសនីដនសាហុង និងគម្រោងវារីអគ្គិសនីសាយ៉ាបូរី ដែលរបស់ឡាវ នៅលើដងទន្លេមេនៃទន្លេមេគង្គ (ទី២) គម្រោងវារីអគ្គិសនី Itaipu" នៅប្រទេសប្រេហ្ស៊ីល និង (ទី៣) គណៈកម្មការទន្លេមីស៊ីស៊ីពី សហរដ្ឋអាមេរិក









- **ជាមួយប្រទេសដៃគូសន្ទនា (ចិន និងមីយ៉ាន់ម៉ា)**

√ កម្ពុជា រួមជាមួយប្រទេសជាសមាជិកផ្សេងទៀត ក៏ដូចជាជាមួយលេខាធិការដ្ឋាន MRC បាន យកចិត្តទុកដាក់ខ្ពស់ជាប្រចាំក្នុងការបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូសន្ទនា (ចិន និង មីយ៉ាន់ម៉ា) ជាពិសេសការផ្លាស់ប្តូរ និងចែករំលែកព័ត៌មានគ្នាអំពីការគ្រប់គ្រង និងការអភិវឌ្ឍក្នុងអាងទន្លេមេគង្គ-ឡានឆាង និងការអនុវត្តផែនការនិងសកម្មភាពរួមគ្នា




√ កម្ពុជា និងប្រទេសជាសមាជិកផ្សេងទៀត បានជួបពិភាក្សាគ្នាជាមួយដៃគូសន្ទនា (ចិន និង មីយ៉ាន់ម៉ា) នៅក្នុង កិច្ចប្រជុំជាមួយដៃគូសន្ទនា លើកទី២៨ ដោយបានរួមគ្នា ពិនិត្យវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការរវាងMRC ជាមួយដៃគូសន្ទនា (ចិន និងមីយ៉ាន់ម៉ា) លើការចែករំលែកព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក ភាគខាងលើអាងទន្លេមេគង្គ វឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សិក្សារួមគ្នាលើការប្រែប្រួលរបបជលសាស្ត្រ នៃអាងទន្លេមេគង្គ-ឡានឆាង និងយុទ្ធសាស្ត្របន្សាំ វឌ្ឍនភាពនៃការរៀបចំផែនការបុរេសកម្មតំបន់, ការធ្វើឱ្យប្រសើរឡើងក្របខណ្ឌគាំទ្រសេចក្តីសម្រេចចិត្ត និងយន្តការទំនាក់ទំនងសម្រាប់ការចែករំលែកទិន្នន័យ និងព័ត៌មានសម្រាប់ប្រតិបត្តិការទំនប់វារីអគ្គិសនី វឌ្ឍនភាពនៃកិច្ចសហប្រតិការធនធានទឹកឡានឆាង-មេគង្គ និងការផ្តល់ព័ត៌មានស្តីពីលក្ខខណ្ឌជលសាស្ត្រ និងបរិស្ថាន ក្នុងអាងទន្លេមេគង្គក្នុងអំឡុងខែមករា-សីហា ឆ្នាំ២០២៤







- √ ក្រុមការងារកម្ពុជា បានផ្តល់កិច្ចសហការ និងការចូលរួមក្នុងការពិនិត្យ និងពិភាក្សា លើការអនុវត្តការសិក្សារួមគ្នា ស្តីពីការប្រែប្រួលស្ថានភាពជលសាស្ត្រក្នុងអាងទន្លេមេគង្គ-ឡានឆាង និងយុទ្ធសាស្ត្របន្សាំដែលបច្ចុប្បន្នស្ថិតក្នុងដំណាក់កាលទី២
- √ ក្រុមការងារកម្ពុជា ក៏បានសម្របសម្រួល និងចូលរួមដំណើរអង្កេតរួមគ្នាលើកទី២ ដែលជាផ្នែកមួយនៃសិក្សារួមគ្នា ស្តីពីការប្រែប្រួល ស្ថានភាពជលសាស្ត្រក្នុងអាងទន្លេមេគង្គ-ឡានឆាង និងយុទ្ធសាស្ត្របន្សាំ ទៅកាន់តំបន់កំពង់ភ្លុក បឹងទន្លេសាប ប្រទេសកម្ពុជា និងដីសណ្តរមេគង្គ ប្រទេសវៀតណាម

ជារួម នៅក្នុងជំនួបប្រចាំឆ្នាំ និងការពិនិត្យវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូសន្ទនា, កម្ពុជា ក៏ដូចជាប្រទេសជាសមាជិកផ្សេងទៀត បានវាយតម្លៃខ្ពស់នៃកិច្ចសហប្រតិបត្តិការរវាង MRC និងប្រទេសដៃគូសន្ទា ដែលសម្រេចបាននាពេលកន្លងមក និងបានស្នើឱ្យខិតខំពង្រឹង និងធ្វើឱ្យកាន់តែប្រសើរថែមទៀត ជាពិសេសការចែករំលែករវាងគ្នានឹងគ្នានូវទិន្នន័យ និងព័ត៌មាន ដើម្បីទ្រទ្រង់ដល់កិច្ចខិតខំប្រឹងប្រែងរួមគ្នា សំដៅធ្វើឱ្យការរៀបចំផែនការ និងការគ្រប់គ្រងអាងទន្លេ និងធនធានក្នុងអាងបានកាន់តែប្រសើរ មានប្រសិទ្ធភាព រួមទាំងការដោះស្រាយបញ្ហាប្រឈមដែលបាននិងកំពុងកើតមានក្នុងអាងនាពេលបច្ចុប្បន្ន និងទៅអនាគត ក្នុងបរិបទអាកាសធាតុប្រែប្រួលឥតឈប់ឈរ។ ចំណែកឯដៃគូសន្ទនា, ក៏តែងបានអបអរសាទរចំពោះការខិតខំប្រឹងប្រែងរបស់ MRC និងចំពោះវឌ្ឍនភាពការងារ និងសមិទ្ធផលដែលសម្រេចបាន និងបានប្តេជ្ញាបន្តពង្រឹងកិច្ចសហការជាមួយ MRC លើការចែករំលែកព័ត៌មាន និងការសិក្សារួមគ្នាលើបម្រែបម្រួលរបបជលសាស្ត្រ ក្នុងអាងទន្លេមេគង្គ-ឡានឆាង។

- **ជាមួយប្រទេសដៃគូអភិវឌ្ឍន៍**






- √ កម្ពុជា រួមជាមួយប្រទេសជាសមាជិកផ្សេងទៀត បានជួបពិភាក្សាគ្នាជាមួយប្រទេសដៃគូអភិវឌ្ឍន៍ នៅក្នុងវេទិកាប្រចាំឆ្នាំរួមមាន៖ ទី១) កិច្ចប្រជុំពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ លើកទី២៩ ទី២) កិច្ចប្រជុំពិគ្រោះយោបល់ក្រៅផ្លូវការជាមួយប្រទេសដៃគូអភិវឌ្ឍន៍ លើកទី១២ និងទី៣) កិច្ចប្រជុំពាក់ព័ន្ធសំខាន់ផ្សេងទៀតដូចជាការពិនិត្យវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រ ២០២១-២០២៥ ការរៀបចំផែនការការងារពហុឆ្នាំ២០២៥-២០២៦ ជាដើម។ ជារួម៖



- ប្រទេសជាសមាជិក MRC បានថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅ និងវាយតម្លៃខ្ពស់ចំពោះដៃគូអភិវឌ្ឍន៍ ដែលបានបន្តគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ដែលបានផ្តល់លទ្ធភាពដល់ MRC អាចអនុវត្តកិច្ចការជាអាទិភាពរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព ឆ្ពោះទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្នុងអាងទន្លេមេគង្គ
- ដៃគូអភិវឌ្ឍន៍ បានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលការងារដែល MRC បានអនុវត្ត និងសម្រេចបាន និង ដៃគូអភិវឌ្ឍន៍ បានអះអាងសារជាថ្មី នូវការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីបន្តគាំទ្រដល់ MRC និងធ្វើកិច្ចសហប្រតិបត្តិការជាមួយប្រទេសជាសមាជិក MRC ក្នុងការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងអាងទន្លេមេគង្គ។

- ប្រទេសជាសមាជិក និងដៃគូអភិវឌ្ឍន៍ បានប្តេជ្ញារួមគ្នាបន្តពង្រឹងភាពជាដៃគូ និងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ក្នុងស្មារតីនៃកិច្ចសហប្រតិបត្តិការឱ្យបានកាន់តែរឹងមាំ និងប្រសើរថែមទៀត ដើម្បីរួមគ្នាដោះស្រាយបញ្ហាប្រឈមដែលបាននិងកំពុងកើតមានក្នុងអាង ឱ្យមានប្រសិទ្ធភាព ដើម្បីអាងទន្លេមេគង្គ មានសន្តិសុខទឹក និងដោយចីរភាព សម្រាប់ពេលបច្ចុប្បន្ន និងទៅអនាគត ។

### ខ.២. កិច្ចសហប្រតិបត្តិការក្រោមយន្តការកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងមេគង្គ និងដៃគូផ្សេងទៀត

គ.ជ.ទ.ម.ក បានចូលរួម ពង្រឹង និងផ្តល់កិច្ចសហការសម្រាប់យន្តការកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងមេគង្គ និងដៃគូសហការផ្សេងទៀត ដែលមានសកម្មភាព និងកិច្ចសហប្រតិបត្តិការ បានអនុវត្តដូចខាងក្រោម៖

#### ខ.២.១. ក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង



- បានទទួលអនុវត្តគម្រោងថ្មីក្រោមមូលនិធិពិសេស នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងហានិភ័យទឹកជំនន់សម្រាប់ការអភិវឌ្ឍកសិកម្ម ផ្អែកលើផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនៅស្ទឹងសែនដែលជាដៃនៃបឹងទន្លេសាប
- បាន និងកំពុងបន្តអនុវត្តគម្រោង ក្រោមមូលនីធិពិសេសនៃកិច្ចសហ-ប្រតិបត្តិការមេគង្គ-ឡានឆាង រួមមាន៖ (ទី១) ″ការគ្រប់គ្រងធនធានទឹក និងធនធានពាក់ព័ន្ធឆ្លងដែន ដោយមានការចូលរួមពីសហគមន៍ នៅតំបន់ព្រំដែនដីសណ្តទន្លេមេគង្គកម្ពុជា-វៀតណាម និងផ្សព្វផ្សាយបទពិសោធន៍ទទួលបានទៅតំបន់ព្រំដែនកម្ពុជា ឡាវ″ (ទី២) ″ការត្រួតពិនិត្យគុណភាពទឹក និងការវាយតម្លៃទឹកជំនន់ និងគ្រោះរាំងស្ងួតនៅតាមដងទន្លេមេគង្គក្នុងប្រទេសកម្ពុជា និងការបង្កើតមជ្ឈមណ្ឌលព័ត៌មាន″ និង

(ទី៣) " ការកសាងយន្តការ និងបច្ចេកវិទ្យាសម្រាប់គ្រោះមហន្តរាយទឹកជំនន់ នៅតំបន់ទន្លេសេសាន នៅភូមិភាគឦសាន្ត នៃប្រទេសកម្ពុជា"

- ក្រុមមន្ត្រីអន្តរក្រសួង-ស្ថាប័ន រួមមានមន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក និងក្រសួងធនធានទឹក និងឧតុនិយម បានចូលរួមកិច្ចប្រជុំលើកទី១ នៃក្រុមអ្នកជំនាញរួម MRC-LMC ផ្នែកទិន្នន័យ ម៉ូដែល និងការព្យាករណ៍ ស្តីពីការប្រែប្រួល ស្ថានភាពជលសាស្ត្រក្នុងអាងទន្លេមេគង្គ-ឡានឆាង និងយុទ្ធសាស្ត្របន្សាំ និងក៏បានសម្របសម្រួលការចុះអង្កេតរួមគ្នាមេគង្គ-ឡានឆាង លើកទី២ នៅបឹងទន្លេសាប


Lancang-Mekong Cooperation Special Fund
Project Proposal





## ខ.២.២. ក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-កូរ៉េ

- បានរៀបចំឯកសារសំណើគម្រោង (Project Proposal) ដើម្បីស្នើសុំមូលនិធិកិច្ចសហប្រតិបត្តិការមេគង្គ-សាធារណរដ្ឋកូរ៉េ សម្រាប់ជុំទី៨ ចំនួន ១ គម្រោង គឺ "ការគ្រប់គ្រងហានិភ័យទឹកជំនន់សម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម ផ្អែកលើផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុនៅស្ទឹងសែនដែលជាដៃបឹងទន្លេសាប"






- ក្រុមការងារកម្ពុជា រួមជាមួយក្រុមការងារនៃប្រទេសឡាវ ថៃ និងវៀតណាម បានទៅទស្សនកិច្ចសិក្សានៅកូរ៉េ ដើម្បីពង្រឹងជំនាញ និងបទពិសោធន៍ការងារដល់ ក្រុមការងារថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានលើការប្រើប្រាស់បច្ចេកវិទ្យា និងការអនុវត្តជាក់ស្តែងប្រកបដោយនិរន្តរភាព ក្នុងការដោះស្រាយបញ្ហាប្រឈមទាក់ទងនឹងទឹក ថាមពល និងស្បៀងក្នុងដំណើរការគម្រោងសាកល្បងតាមប្រទេសរៀងៗខ្លួន។

### ខ.២.៣. ក្របខណ្ឌកិច្ចសហប្រតិបត្តិការភាពជាដៃគូមេគង្គ-សហរដ្ឋអាមេរិក



- មន្ត្រីថ្នាក់អគ្គលេខាធិការដ្ឋាន បានចូលរួមជាមួយគណៈប្រតិភូគណៈកម្មការទន្លេមីស៊ីស៊ីពីនៃសហរដ្ឋអាមេរិក ទស្សនកិច្ចផ្លាស់ប្តូរបទពិសោធន៍ ក្រោមកម្មវិធីភាពជាដៃគូរវាង MRC និងគណៈកម្មការទន្លេមីស៊ីស៊ីពី ទៅកាន់នៅប្រទេសថៃ និងវៀតណាម នៅចុង ខែមករា ឆ្នាំ២០២៤ ដើម្បីស្វែងយល់អំពីរបៀបរបប ក្នុងរៀបចំទុកដាក់ទិន្នន័យជលសាស្ត្រ និងការបង្កើតមជ្ឈមណ្ឌលទិន្នន័យរួមការព្យាករណ៍ និងជូនដំណឹងពីទឹកជំនន់ និងស្វែងយល់អំពីការរៀបចំ និងអនុវត្តផែនការមេ សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍតំបន់ដីសណ្តរមេគង្គ ក្នុងនោះ ក៏មានការគ្រប់គ្រងការជ្រៀបចូលនូវទឹកប្រៃផងដែរ និងបានចុះពិនិត្យ និងស្វែយយល់ពីតំបន់ដីសើម ជាពិសេសគឺ តំបន់អភិរក្សព្រៃកោងកាង នៅតំបន់ដីសណ្តមេគង្គ រួមទាំងការធ្វើអាជីវកម្មចិញ្ចឹមត្រី



- មន្ត្រីថ្នាក់អគ្គលេខាធិការដ្ឋាន បានចូលរួមក្នុងប្រតិភូ MRC ក្នុងដំណើរទស្សនកិច្ចផ្លាស់ប្តូរភាពជាដៃគូរវាង MRC និងគណៈកម្មការទន្លេមីស៊ីស៊ីពី នៅសហរដ្ឋអាមេរិក ដើម្បីផ្លាស់ប្តូរបទពិសោធន៍លើការគ្រប់គ្រងអាងទន្លេការដឹកជញ្ជូនតាមផ្លូវទឹក ការគ្រប់គ្រងទឹកជំនន់ និងដំណោះស្រាយផ្អែកលើធម្មជាតិ




- មន្ត្រីថ្នាក់អគ្គលេខាធិការដ្ឋាន បានចូលរួមកិច្ចប្រជុំផ្តល់យោបល់ និងធាតុចូល ពាក់ព័ន្ធនឹងសេចក្តីព្រាងឯកសារសំខាន់ចំនួនពីរ (១) Mekong-U.S Partnership Co-chair Concept Note for 2023 Policy dialogue 2023 MUSP Co-chairs-Lao PDR and the United States និង (២) Mekong-U.S Partnership Plan of Action 2024-2026



- មន្ត្រីថ្នាក់អគ្គលេខាធិការដ្ឋាន បានចូលរួមក្នុងកិច្ចសន្ទនាគោលនយោបាយភាពជាដៃគូមេគង្គ-អាមេរិកឆ្នាំ ២០២៤ នៅប្រទេសឡាវ ដោយបានធ្វើការផ្លាស់ប្តូរទស្សនៈគ្នា ស្តីពីអាទិភាពប្រចាំឆ្នាំរួមគ្នា សម្រាប់ភាពជាដៃគូមេគង្គ-អាមេរិក

- មន្ត្រីថ្នាក់អគ្គលេខាធិការដ្ឋាន និងក្រសួងធនធានទឹក និងឧតុនិយម បានចូលរួមក្នុងពិធីអបអរសាទរលើសមិទ្ធផល និងកិច្ចសហប្រតិបត្តិការរវាង USAID-ADPC-MRC ស្តីពីការប្រើប្រាស់ផ្កាយរណបសម្រាប់ការគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួត ។

### ខ.២.៤.ក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-គង្គា

- មន្ត្រីថ្នាក់អគ្គលេខាធិការដ្ឋាន ១ រូបត្រូវបានចាត់ជាសមាជិកក្រុមការងារផ្នែកការគ្រប់គ្រងធនធានទឹកនៃកិច្ចសហប្រតិបត្តិការមេគង្គ-គង្គា និងបានចូលរួមកិច្ចប្រជុំក្រុមការងារលើកទី១ ស្តីពីការគ្រប់គ្រងធនធានទឹក
- បានផ្តល់យោបល់ និងធាតុចូលលើសេចក្តីព្រាងទស្សនទានស្តីពី "ឆ្នាំនៃការផ្លាស់ប្តូរ សម្រាប់យន្តការមេគង្គ-គង្គា ២០២៥ (Mekong-Ganga Cooperation (MGC) Year of Exchange in 2025)" ។

### ខ.២.៥.ក្របខណ្ឌកិច្ចសហប្រតិបត្តិការពាក់ព័ន្ធលើការងារមេគង្គ ជាមួយអូស្ត្រាលី

- មន្ត្រីថ្នាក់អគ្គលេខាធិការដ្ឋាន ១ រូប ត្រូវបានចាត់ជាអនុប្រធានក្រុមការងារអន្តរស្ថាប័ន និងបានចូលរួមពិនិត្យ និងពិភាក្សាដើម្បីរៀបចំសំណើកម្មវិធីផ្តល់មូលនិធិថ្មីរបស់អូស្ត្រាលី លើផ្នែកបន្សាំអាកាសធាតុនៅកម្ពុជា ក្រោមជំនួយឧបត្ថម្ភរបស់ប្រទេសអូស្ត្រាលី។



### ខ.២.៦.ក្របខណ្ឌកិច្ចសហប្រតិបត្តិការ MRC-អាស៊ាន

- ប្រតិភូកម្ពុជាចំនួន ៦ រូប មកពីក្រសួងធនធានទឹក និងឧតុនិយម និងអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក បានចូលរួមក្នុងវេទិកាកិច្ចសន្ទនាសន្តិសុខទឹក MRC-អាស៊ាន លើកទី២ ក្រោមមូលបទ "ការវិនិយោគដោយចីរភាព សម្រាប់អាស៊ីអាគ្នេយ៍ដែលមានការតភ្ជាប់ ភាពធន់ និងសន្តិសុខទឹក"។ ក្នុងឱកាសនៃការចូលរួមវេទិកាកិច្ចសន្ទនានោះ ឯកឧត្តមអគ្គលេខាធិការ គ.ជ.ទ.ម.ក ត្រូវបានចាត់ជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធាន គ.ជ.ទ.ម.ក បានថ្លែងសុន្ទរកថាគន្លឹះ ដោយផ្តោតលើបញ្ហាប្រឈមផ្នែកសន្តិសុខទឹក ដំណោះស្រាយលើការគ្រប់គ្រងធនធានទឹកដោយចីរភាព និងការជំរុញលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ



- មន្ត្រីអគ្គលេខាធិការដ្ឋាន បានចូលរួមពិធីចុះហត្ថលេខាលើអនុស្សារណៈនៃគោលបំណង ស្ដីពីកិច្ចសហការ រវាងលេខាធិការដ្ឋាន MRC និងមជ្ឈមណ្ឌលសម្របសម្រួលអាស៊ាន សម្រាប់ជំនួយមនុស្សធម៌ លើផ្នែកគ្រប់គ្រងគ្រោះមហន្តរាយ។






### ខ.២.៧.ក្របខណ្ឌកិច្ចសហប្រតិបត្តិការជាមួយ IUCN

- បានចូលរួម និងផ្ដល់កិច្ចសហការក្នុងការរៀបចំគម្រោង ស្ដីពីការលើកកម្ពស់ការគ្រប់គ្រងជលផលឆ្លងដែនក្នុងអាងទន្លេមេគង្គក្រោម ក្នុងក្របខណ្ឌ MRC ក្រោមមូលនិធិបរិស្ថានសាកល (GEF) ដែលមាន IUCN ជាស្ថាប័ន Accredited Entity



### ខ.២.៨.ក្របខណ្ឌកិច្ចសហប្រតិបត្តិការគម្រោងឆ្លងដែន ក្រោមការគាំទ្រមូលនិធិរបស់ GIZ

- ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដឹកនាំដោយក្រសួងធនធានទឹក និងឧតុនិយម និងសម្របសម្រួលដោយ គ.ជ.ទ.ម.ក បានចូលរួមកិច្ចប្រជុំ រៀបចំយន្តការ និងពិនិត្យលើកិច្ចព្រមព្រៀងរួមគ្នាសម្រាប់អនុវត្តគម្រោងកិច្ចសហប្រតិបត្តិការឆ្លងដែនកម្ពុជានិងថៃ នៅតំបន់ 9C និង 9T ដំណាក់កាលទី៣ និងអនុវត្តបន្តនៅតំបន់ទន្លេសេកុង សេសាន និងស្រែពក (3S) ។






### ខ.២.៩.ក្របខណ្ឌកិច្ចសហប្រតិបត្តិការ ACMECS

- បានចូលរួមផ្តល់យោបល់លើឯកសារសេចក្តីព្រាងទស្សនទាន ស្តីពី "Water Resources Management in the Mekong Region" ជាធាតុចូលរបស់ក្រសួងធនធានទឹក និងឧតុនិយម ផ្ញើជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

### ខ.២.១០.ក្របខណ្ឌកិច្ចសហប្រតិបត្តិការកម្ពុជា-ឡាវ

- បានរៀបចំ និងផ្តល់របាយការណ៍វឌ្ឍនភាពចំពោះកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ឡាវ ពាក់ព័ន្ធនឹងការងារ គ.ជ.ទ.ម.ក តាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការរៀបចំជាឯកសារជំនួយស្មារតី សម្រាប់ជំនួបទ្វេភាគីរបស់ថ្នាក់ដឹកនាំប្រទេសក្នុងដំណើរទស្សនកិច្ចផ្លូវការ ។

### ខ.២.១១.ក្របខណ្ឌកិច្ចសហប្រតិបត្តិការកម្ពុជា-ថៃ

- កម្ពុជា និងថៃ បាននិងកំពុងអនុវត្តគម្រោងរួមគ្នា ស្តីពីកិច្ចសហប្រតិបត្តិការឆ្លងដែន សម្រាប់ការគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួត នៅតំបន់ព្រំដែនកម្ពុជា-ថៃ ក្នុងអនុអាង 9C និង 9T ដោយបានបង្ហាញពីចក្ខុវិស័យជាយុទ្ធសាស្ត្រ រយៈពេល ២០ឆ្នាំ ផែនការសកម្មភាព ១៥ឆ្នាំ និងកម្មវិធីតាមកាលវិភាគរយៈពេល ៥ឆ្នាំចុងក្រោយ សម្រាប់ ២០២២-២០២៦។ តាមរយៈនៃគម្រោងឆ្លងដែននេះ បង្កើតបាននូវផែនការមេ សម្រាប់ការគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួតនៅក្នុងអនុអាង 9C-9T ដោយផ្តោតលើអាទិភាពយុទ្ធសាស្ត្រទាំង៥ គឺ៖ (១) ការពិនិត្យ ធ្វើបច្ចុប្បន្នភាព និងអនុវត្តផែនការមេអាង 9C-9T (២) ការគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួតនៅទីក្រុង និងជនបទ ដើម្បីកាត់បន្ថយហានិភ័យ (៣) ការផ្លាស់ប្តូរព័ត៌មាន និងចំណេះដឹង (៤) ពង្រឹងបណ្តាញស្ថានីយជលសាស្ត្រ-ឧតុនិយម និងការជូនដំណឹងជាមុនអំពីទឹកជំនន់ និងភាពរាំងស្ងួត និង (៥) ការកសាងសមត្ថភាពក្នុងតំបន់។ ក្រោមគម្រោង ក្រុមការងារនៃប្រទេសទាំងពីរ បានជួបប្រជុំនិងទទួលបានការបណ្តុះបណ្តាល ជាបន្តបន្ទាប់ ស្តីពីការគ្រប់គ្រងទឹកជំនន់និងភាពរាំងស្ងួត និងប្រទេសទាំងពីរនឹងរៀបចំជាអនុស្សារណៈ ស្តីពីការយោគយល់គ្នា ស្តីពី កិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងការអភិវឌ្ឍដោយចីរភាពផ្នែកអេកូឡូស៊ីនៃអនុអាង 9C-9T ។

### ខ.២.១២.ក្របខណ្ឌកិច្ចសហប្រតិបត្តិការកម្ពុជា-វៀតណាម

- បានជួយសម្របសម្រួលឱ្យមានកិច្ចប្រជុំទ្វេភាគី ដើម្បីពិនិត្យនិងពិភាក្សាវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងរវាងកម្ពុជានិងវៀតណាម លើវិស័យដឹកជញ្ជូនតាមផ្លូវទឹក និងដើម្បីបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី និងពិភាក្សាអំពីសកម្មភាពរបស់ MRC ដើម្បីជួយសម្រួលដល់ការអនុវត្តកិច្ចព្រមព្រៀងឱ្យ





កាន់តែមានប្រសិទ្ធភាពថែមទៀត

- បានរៀបចំ និងផ្តល់របាយការណ៍វឌ្ឍនភាពចំពោះកិច្ចសហប្រតិបត្តិការទ្វេភាគី កម្ពុជា-វៀតណាម ពាក់ព័ន្ធនឹងការងារ គ.ជ.ទ.ម.ក និងការផ្តល់ធាតុចូលសម្រាប់សេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំលើកទី២១ នៃគណៈកម្មការចម្រុះកម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដែលកម្ពុជាជាប្រទេសម្ចាស់ផ្ទះ តាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទទួលនូវសេចក្តីជូនដំណឹងជាប្រចាំអំពីសេចក្តីជូនដំណឹង និងបានចែកផ្សាយបន្តជូនក្រសួង អាជ្ញាធរខេត្ត និងមន្ទីរពាក់ព័ន្ធ ក្នុងខេត្តស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី ស្តីពីការបញ្ចេញជារទឹកពីអាងស្តុកទឹកសេសាន ៤ និង ៤ អេ និងស្រែពក របស់វៀតណាម ។

### ខ.២.១៣.ក្របខណ្ឌកិច្ចសហការការងារជាមួយដៃគូពាក់ព័ន្ធផ្សេងទៀត



- មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក បានចូលរួមក្នុងវេទិកាទឹកពិភពលោក លើកទី១០ ក្រោមមូលបទ“ទឹកដើម្បីភាពចម្រុងចម្រើនរួមគ្នា” ដែលបានប្រព្រឹត្តទៅពីថ្ងៃទី១៨-២៥ ខែឧសភា ឆ្នាំ២០២៤ នៅទីក្រុងបាលី ប្រទេសឥណ្ឌូនេស៊ី ដោយបានចូលរួមជាវាគ្មិនតំណាង MRC ក្នុងវគ្គ Bridge Building Through Transboundary Water Finance និងបានផ្តល់បទអន្តរាគមន៍គន្លឹះខ្លីស្តីពី “ឱកាសផ្តល់ហិរញ្ញប្បទានសម្រាប់យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេមេគង្គ របស់MRC ឆ្នាំ២០២១-២០៣០”។

ក្រៅពីកិច្ចការក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការ និងជាមួយដៃគូពាក់ព័ន្ធ ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក ក៏បានចូលរួមព្រឹត្តិការណ៍ និងសកម្មភាពសង្គមសំខាន់ៗមួយចំនួន ដូចជា៖



- ពិធីអបអរសាទរការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**



- ព្រះរាជពិធីបុណ្យអុំទូក ក្រោមព្រះរាជធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាជា អម្ចាស់ជីវិតតម្កល់លើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**



- បានចូលរួមព្រះរាជពិធីប្រទានភ្លើងជ័យ អបអរសាទរខួបអនុស្សាវរីយ៍លើកទី៧១ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ
- បានចូលរួមដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធនិងថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះបរមរតនកោដ្ឋ



- បានចូលរួមក្នុងព្រះរាជពិធីបុណ្យអុំទូកឆ្នាំ២០២៤ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**
- បានគាំទ្រ និងចូលរួមក្នុងមូលនិធិកសាងហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ព្រំដែន
- មន្ត្រីអគ្គលេខាធិការដ្ឋាន ៣រូប បានចូលរួមបរិច្ចាកឈាម ក្នុងកម្មវិធីបរិច្ចាកឈាមដោយស្ម័គ្រចិត្តរបស់មហាគ្រួសារក្រសួងធនធានទឹក និងឧតុនិយម
- បានចូលរួមការធ្វើតេស្តរហ័សរកសារជាតុញៀនតាមទឹកមូត្រ។






## គ. ការពង្រឹងសមត្ថភាព និងការបណ្តុះបណ្តាល

- បានកសាង និងពង្រឹងសមត្ថភាពមន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក និងក្រសួង ស្ថាប័នពាក់ព័ន្ធ តាមរយៈនៃការរៀបចំ និងចាត់មន្ត្រីចូលរួមសិក្ខាសាលា/វគ្គបណ្តុះបណ្តាលនៅថ្នាក់ជាតិ បានចំនួន ១២ វគ្គ មានមន្ត្រីចូលរួមចំនួន ១៣៦ រូប (ស្ត្រី ៤២ រូប) និងនៅថ្នាក់តំបន់ បានចំនួន ១៨ វគ្គ ដោយមានមន្ត្រីកម្ពុជា បានចូលរួមសរុបចំនួន ៧២ រូប (ស្ត្រី ១១ រូប) ដោយផ្តោតលើជំនាញផ្នែកការប្រើប្រាស់ឧបករណ៍ ការព្យាករណ៍ ការពិនិត្យតាមដានទឹកជំនន់ ភាពរាំងស្ងួត ការបញ្ជ្រាបយេនឌ័រ និងការប្រែប្រួលអាកាសធាតុក្នុងវិស័យធនធានទឹក ការតាមដានជលផល ការតាមដានប្រព័ន្ធអេកូឡូស៊ី ការតាមដានគុណភាពទឹក ការវិភាគម៉ៃក្រូប្លាស្ទិក ការកសាងផែនការចក្ខុវិស័យរួម ការធ្វើម៉ូដែលទឹកក្រោមដី ការប្រើប្រាស់ក្របខណ្ឌសេចក្តីសម្រេចចិត្ត និងគណនេយ្យភាពទឹក សៀវភៅក្បួនណែនាំសម្រាប់ការគ្រប់គ្រងនាវា កំពង់ផែ និងកាកសំណល់ ការពិនិត្យតាមដានវាយតម្លៃសកម្មភាពការងារ ថវិកាសមិទ្ធកម្ម សវនកម្មសមិទ្ធកម្ម និងការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈជាដើម
- មន្ត្រីជំនាញវ័យក្មេងកម្ពុជាចំនួន ៣ រូប ពីក្រសួងធនធានទឹក និងឧតុនិយម និងអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក បានទទួលការបណ្តុះបណ្តាលជំនាញ រយៈពេល ១ឆ្នាំ នៅលេខាធិការដ្ឋាន MRC ក្នុងឆ្នាំ២០២៤ លើជំនាញផ្នែកម៉ូដែល ការព្យាករទឹកជំនន់និងភាពរាំងស្ងួត និងផ្នែកបរិស្ថាន និងបានចាត់បញ្ជូនចំនួន ៣ រូប ទៀត សម្រាប់ឆ្នាំ២០២៥ ខាងមុខ
- មន្ត្រីកម្ពុជា ពីអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក និងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួន សរុប ២៧រូប បានចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សាក្រៅប្រទេស ដើម្បីស្វែងយល់លើការគ្រប់គ្រងទឹក និងទន្លេឆ្លងដែន ទៅកាន់សាធារណរដ្ឋកូរ៉េ សហរដ្ឋអាមេរិក ប្រទេសចិន ប្រទេសប្រេហ្ស៊ីល និងប្រទេសជាសមាជិករួមមានឡាវ ថៃ និងវៀតណាម។








## ឃ. ការបញ្ជ្រាបយេនឌ័រ ក្នុងការគ្រប់គ្រងអាងទន្លេ និងធនធានទឹកចម្រុះ



- បានរៀបចំ និងអញ្ជើញមន្ត្រីតំណាងក្រសួង-ស្ថាប័ន្ធពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចូលរួមសិក្ខាសាលា និងកិច្ចប្រជុំថ្នាក់ជាតិ លើការងារពាក់ព័ន្ធនឹងសមភាព និងសមធម៌យេនឌ័រ ដែលរួមមាន៖
  - √ របាយការណ៍ជាតិ ស្តីពីការកែលម្អសមភាព សមធម៌យេនឌ័រ និងភាពងាយរងគ្រោះក្នុងសង្គម
  - √ យេនឌ័រ និងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ





- បានចូលរួមរៀបចំប្រារព្ធពិធីអបអរសាទរទិវានារីអន្តរជាតិ ៨ មីនា ខួបលើកទី ១១៣ ក្រោមមូលបទ " ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល "
- បានចាត់មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ទ.ម.ក និងអញ្ជើញមន្ត្រីតំណាងក្រសួង ស្ថាប័ន្ធពាក់ព័ន្ធថ្នាក់ជាតិ ចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ដែលរៀបចំដោយដៃគូសហការ និងភាគីពាក់ព័ន្ធ លើការងារពាក់ព័ន្ធនឹងសមភាព និងសមធម៌យេនឌ័រ ដែលរួមមាន៖








  - √ កម្មវិធីតាមដានទន្លេ និងផែនការសកម្មភាពយេនឌ័ររបស់ MRC រៀបចំដោយលេខាធិការដ្ឋាន MRC
  - √ របាយការណ៍ ស្តីពីការកែលម្អសមភាព សមធម៌យេនឌ័រ និងភាពងាយរងគ្រោះក្នុងសង្គមពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍ធនធានទឹក និងការប្រែប្រួលអាកាសធាតុនៅក្នុងអាងទន្លេមេគង្គ រៀបចំដោយលេខាធិការដ្ឋាន MRC
  - √ ការចែករំលែក និងរៀនសូត្រ ស្តីពីឧបករណ៍វាយតម្លៃហេតុប៉ះពាល់យេនឌ័រ ដែលរៀបចំឡើងដោយ អង្គការ Oxfam
  - √ ការបង្កើនចំណេះដឹង លើការសរសេររបាយការណ៍ ក្នុងវិស័យធនធានទឹក ឆ្លើយតបនឹងយេនឌ័រ ដែលរៀបចំដោយក្រសួងធនធានទឹក និងឧតុនិយម។
- √ បានសហការរៀបចំសៀវភៅមគ្គុទេសក៍ ស្តីពីការបញ្ជ្រាបយេនឌ័រ នៅក្នុងសកម្មភាព និងមុខងារស្នូលរបស់ MRC។

## ង. ផលិតផលក្នុងឆ្នាំ ២០២៤ គាំទ្រដល់កិច្ចដំណើរការ ការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងអាងទន្លេមេគង្គ

- កម្ពុជារួមសហការជាមួយប្រទេសជាសមាជិកផ្សេងទៀត ដែលមានការគាំទ្រផ្នែកបច្ចេកទេស និងរដ្ឋបាលពីលេខាធិការដ្ឋាន MRC បានរួមគ្នារៀបចំ បង្កើតបាននូវឯកសារផ្នែកគោលនយោបាយ និងបច្ចេកទេស ក៏ដូចជារបាយការណ៍ ដើម្បីរួមគ្នាអនុវត្ត លើកកម្ពស់ការយល់ដឹង និងសម្រាប់គាំទ្រដល់ការរៀបចំផែនការ បង្កើនប្រសិទ្ធភាពនៃការអភិវឌ្ឍ ការគ្រប់គ្រង ការប្រើប្រាស់ និងការអភិរក្សធនធានទឹក និងធនធានពាក់ព័ន្ធក្នុងអាងទន្លេមេគង្គ ដែលរួមមាន៖

- **ឯកសារ ផ្នែកគោលនយោបាយ**
  - √ របាយការណ៍ MRC ឆ្នាំ២០២៣
  - √ ផែនការពហុឆ្នាំ របស់ MRC ឆ្នាំ ២០២៥-២០២៦
  - √ របាយការណ៍ ស្តីពីស្ថានភាពអាងទន្លេមេគង្គ ឆ្នាំ២០២៣
  - √ ផែនទីអាងទន្លេមេគង្គភាគខាងក្រោម ឆ្នាំ២០២៣
  - √ របាយការណ៍លទ្ធផលនៃការសិក្សារួមគ្នាលើបម្រែបម្រួលរបបជលសាស្ត្រ និងយុទ្ធសាស្ត្របន្សាំ ក្នុងអាងទន្លេមេគង្គ-ឡានឆាង
  - √ សេចក្តីព្រាងផែនការបុរេសកម្មថ្នាក់តំបន់ ដោយរួមមានរបាយការណ៍សិក្សាផ្នែក៖ (១) ជម្រើសនៃការស្តុកទឹក (Water storage options) (២) បម្រែបម្រួលស្ថានភាពជលសាស្ត្រសម្រាប់ធនធានដីសើម (Hydrological Limits of Change for Key Wetland Assets) (៣) បញ្ហាពាក់ព័ន្ធនឹងកំណកកករដី (Sediment-Related Issues) និង (៤) សមាហរណកម្មទឹក-ថាមពល (Water-Energy Integration)
  - √ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់ការសាកល្បងអនុវត្តដោយស្ម័គ្រចិត្ត នៃគោលការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនសម្រាប់គម្រោងទំនប់វារីអគ្គិសនី សេកុង A របស់ឡាវ
  - √ សេចក្តីព្រាងរបាយការណ៍ វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព និងផែនការគម្រោងដើម្បីពង្រឹងការគ្រប់គ្រងធនធានបរិស្ថានដែលមានសារៈសំខាន់ថ្នាក់តំបន់
  - √ សេចក្តីព្រាងរបាយការណ៍ការគ្រប់គ្រងទីជម្រាលសំខាន់ៗក្នុងអាងទន្លេមេគង្គក្រោម
- **ឯកសារ ផ្នែកបច្ចេកទេស**
  - √ គោលការណ៍ណែនាំបច្ចេកទេសបច្ចុប្បន្នភាព ស្តីពីភាពទុកដាក់ទិន្នន័យ និងការគ្រប់គ្រងប្រព័ន្ធព័ត៌មាន MRC

- សេចក្តីព្រាងបច្ចុប្បន្នភាពនៃគោលការណ៍ណែនាំសម្រាប់នីតិវិធីស្តីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង
- សេចក្តីព្រាងគោលការណ៍ ស្តីពីការបន្សាំនឹងភាពរាំងស្ងួត ក្នុងអាងទន្លេមេគង្គក្រោម
- សេចក្តីព្រាងគោលការណ៍បច្ចេកទេស ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ទឹកក្រោមដីប្រកបដោយចីរភាព សម្រាប់វិស័យកសិកម្ម
- បច្ចុប្បន្នភាពក្របខណ្ឌលំហូរសម្រាប់នីតិវិធីរបស់ MRC ស្តីពីការថែរក្សាជារទឹកនៅលើទន្លេមេ
- របាយការណ៍មេគង្គប្រចាំឆ្នាំ២០២៣ ផ្នែកជលសាស្ត្រ ទឹកជំនន់ និងភាពរាំងស្ងួត
- របាយការណ៍គុណភាពទឹក ឆ្នាំ២០២៣
- របាយការណ៍បឋម ស្តីពីឧប្បត្តិហេតុនៃការលេចធ្លាយសារធាតុគីមីចូលទៅក្នុងទន្លេណាមខាន់នៅខេត្តហ្លួងប្រាបាង ប្រទេសឡាវ
- របាយការណ៍ ស្តីពីការវាយតម្លៃតម្រូវការ និងផែនការកសាងសមត្ថភាពសម្រាប់ការអនុវត្តកម្មវិធីតាមដានសារធាតុប្លាស្ទិក
- សេចក្តីព្រាងរបាយការណ៍ ស្តីពីមូលដ្ឋានទិន្នន័យនៃសារពើភ័ណ្ឌ ទំនិញគ្រោះថ្នាក់ សម្រាប់គាំទ្រដល់ការអនុវត្ត "គោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រង និងការឆ្លើយតបបន្ទាន់ លើគ្រោះអាសន្នគុណភាពទឹក"
- នីតិវិធិប្រតិបត្តិស្តង់ដារ សម្រាប់ការតាមដានជលផល ក្នុងអាងទន្លេមេគង្គក្រោម
- សេចក្តីព្រាងរបាយការណ៍ ស្តីពីមេរៀនបទពិសោធន៍ទទួលបានពីសហគ្រប់គ្រងជលផល
- សេចក្តីព្រាងរបាយការណ៍ ស្តីពីការសាកល្បងក្នុងការកែលម្អការវាយតម្លៃ និងការសំយោគសំណុំទិន្នន័យ និងព័ត៌មានផលចាប់ជលផល និងការបញ្ចូលទៅក្នុងការរៀបចំគោលនយោបាយ ផែនការ និងការវិនិយោគថ្នាក់ជាតិ
- របាយការណ៍ ស្តីពីការអង្កេតតាមដានជីវសាស្ត្រឆ្នាំ២០២៣ ក្នុងអាងទន្លេមេគង្គក្រោម
- សេចក្តីព្រាងរបាយការណ៍ បច្ចុប្បន្នភាពនៃការសាកល្បងប្រើប្រាស់មូលនិធិមេគង្គសម្រាប់ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់មេគង្គ
- សេចក្តីព្រាងរបាយការណ៍ ស្តីពីការធ្វើឱ្យប្រសើរផ្នែកសមភាព សមធម៌យេនឌ័រ និងភាពងាយរងគ្រោះក្នុងសង្គម ក្នុងអាងទន្លេមេគង្គភាគខាងក្រោម
- សៀវភៅមគ្គុទេសក៍ ស្តីពីការបញ្ជ្រាបយេនឌ័រ នៅក្នុងសកម្មភាព និងមុខងារស្នូលរបស់ MRC ។

## ច. ការសិក្សាស្រាវជ្រាវ និងការពង្រឹងលើការពិនិត្យតាមដានទន្លេ និងស្ថានភាពធនធានពាក់ព័ន្ធ ក្នុងអាងទន្លេមេគង្គ





- ក្រុមការងារអន្តរស្ថាប័ន បានសហការអនុវត្តការសិក្សាសាកល្បងនៅថ្នាក់ជាតិ លើការគ្រប់គ្រងការប្រើប្រាស់ទឹក និងធនធានធម្មជាតិ រួមមាន៖
    - √ ការសិក្សាសាកល្បងប្រព័ន្ធពិនិត្យតាមដានការប្រើប្រាស់ទឹក ដែលលទ្ធផលនៃការសិក្សា នឹងផ្តល់ជាធាតុចូលដើម្បីធ្វើបច្ចុប្បន្នភាពម៉ូដែលក្របខណ្ឌគាំទ្រការធ្វើសេចក្តីសម្រេចចិត្ត និងឧបករណ៍ដទៃទៀតសម្រាប់គណនេយ្យទឹក
    - √ ការសិក្សាសាកល្បងប្រព័ន្ធពិនិត្យតាមដានការប្រើប្រាស់ទឹក នៅក្នុងអាងស្ទឹងព្រែកត្នោត ដោយប្រើក្របខណ្ឌគាំទ្រការធ្វើសេចក្តីសម្រេចចិត្ត ដែលបានធ្វើបច្ចុប្បន្នភាពការ
    - √ គម្រោងសិក្សាសាកល្បង ស្តីពីការធ្វើឱ្យប្រសើរលទ្ធភាពទទួលបានទឹកស្អាត និងបង្កើនសន្តិសុខស្បៀង នៅឃុំស្តៅ ស្រុកសេសាន ខេត្តស្ទឹងត្រែង







    - √ ការសិក្សាសាកល្បងដើម្បីពិនិត្យលើការសម្របសម្រួលកិច្ចប្រតិបត្តិការ និងការរៀបចំកិច្ចសហប្រតិបត្តិការ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធទឹកសំខាន់ៗ
    - √ ការចុះសិក្សាស្រាវជ្រាវវាយតម្លៃលើផ្នែកផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការបន្សាំការពឹងអាស្រ័យផលទន្លេមេគង្គ ស្ថានភាពជលសាស្ត្រ ការធ្វើបច្ចុប្បន្នភាពទិន្នន័យ ព័ត៌មាននៅអន្តរតំបន់នៃឋបនីយជីវមណ្ឌលបឹងទន្លេសាប

- ក្រុមការងារអន្តរស្ថាប័នពីកម្ពុជា បានសហការក្នុងក្របខណ្ឌការងារតំបន់ដោយៈ



| [illegible] | [illegible] | កម្ពុជា | ឡាវ | ថៃ | វៀតណាម |
|---|---|---|---|---|---|
| ជលសាស្ត្រ | ៦១ | ១៧ | ២១ | ១២ | ១១ |
| កំណកកករដី | ២៥ | ៨ | ៦ | ៩ | ២ |
| គុណភាពទឹក<br>- ស្វ័យប្រវត្តិ (Automatic)<br>- កត់ដោយដៃ (Manual) | <br>១០<br>៤៥ | <br>៣<br>១៣ | <br>៣<br>១៩ | <br>១<br>៨ | <br>៣<br>៥ |
| សុខភាពអេកូឡូស៊ី | ៣៦ | ១០ | ១២ | ៨ | ៦ |
| ជលផល<br>- [illegible]<br>- [illegible]<br>- [illegible] | <br>៣៨<br>៨<br>១ | <br>១២<br>២<br>១ | <br>១២<br>២<br>០ | <br>៦<br>២<br>០ | <br>៨<br>២<br>០ |





√ បានធ្វើបច្ចុប្បន្នភាព និងសហការពង្រឹងកិច្ចដំណើរការបណ្តាញពិនិត្យតាមដានទន្លេ លើផ្នែកជលសាស្ត្រ កំណកកករល្បាប់ គុណភាពទឹក ជលផល សុខភាពអេកូឡូស៊ី

√ បានចូលរួមក្នុងការធ្វើសង្កេតរួមគ្នាស្ថានភាពជលសាស្ត្រក្នុងអាងទន្លេមេគង្គ-ឡានឆាង ដោយចុះពិនិត្យនៅអាងទន្លេឡានឆាង ក្នុងប្រទេសចិន និងនៅកំពង់ភ្លុក បឹងទន្លេសាប និងស្ថានីយជលសាស្ត្រចតុមុខ ក្នុងប្រទេសកម្ពុជា និងនៅដីសណ្តទន្លេមេគង្គ ក្នុងប្រទេសវៀតណាម។ សកម្មភាពនេះ ជាផ្នែកមួយដើម្បីពិនិត្យផ្ទៀងផ្ទាត់លើលទ្ធផលនៃការសិក្សារួមគ្នាស្តីពីបម្រែបម្រួលជលសាស្ត្រក្នុងអាងទន្លេមេគង្គ-ឡានឆាង និងយុទ្ធសាស្ត្របន្សាំ

√ បានចូលរួមពិភាក្សាលើការរៀបចំក្របខណ្ឌផែនការ និងការគ្រប់គ្រងសម្រាប់ ទីជម្រាលសំខាន់ៗក្នុងអាងទន្លេមេគង្គក្រោម

√ បានចុះពិនិត្យសិក្សាស្វែងយល់ និងផ្លាស់ប្តូរទស្សនៈ និងមេរៀនបទពិសោធន៍លើការប្រើប្រាស់ឧបករណ៍គ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួត នៅខេត្តភូកេត ប្រទេសថៃ

√ បានចុះទស្សនកិច្ចសិក្សាសំណង់ផ្លូវត្រី នៅខេត្តណាំយួង ប្រទេសឡាវ ។






## ឆ. ការលើកកម្ពស់ការយល់ដឹង និងការផ្សព្វផ្សាយ

បានផ្សព្វផ្សាយ និងចែករំលែកជាប្រចាំនូវព្រឹត្តិបត្រព័ត៌មានមេគង្គរបស់ MRC ស្តីពីកម្ពស់ទឹក និងផែនទីរបាយទឹកភ្លៀង ប្រចាំថ្ងៃនៅរដូវវស្សា និងប្រចាំសប្តាហ៍ នៅរដូវប្រាំង

- បានចែករំលែក និងផ្សព្វផ្សាយបន្តជាប្រចាំនូវសេចក្តីជូនដំណឹងស្តីពីស្ថានភាពអាកាសធាតុរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានផ្តល់ព័ត៌មានជាប្រចាំដល់បង្គោលនៃក្រសួង-មន្ទីរ និងអាជ្ញាធរខេត្តពាក់ព័ន្ធ និងបានធ្វើជាផ្លូវការជូនទៅក្រសួង-មន្ទីរ និងអាជ្ញាធរខេត្តពាក់ព័ន្ធ នូវសេចក្តីជូនដំណឹងអំពីការបញ្ចេញធារទឹកពីអាងស្តុកទឹកសេសាន ៤ និង៤អេ ស្តីពីការបញ្ចេញទឹក ដើម្បីផលិតថាមពលវារីអគ្គិសនីរបស់វៀតណាម នៅទន្លេសេសាន និងទន្លេស្រែពក

- បានសហការពិនិត្យ ដើម្បីធ្វើឱ្យប្រសើរប្រព័ន្ធព័ត៌មានថ្នាក់តំបន់ និងថ្នាក់ជាតិ និងបានរៀបចំធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មាន កម្មវិធីគ្រប់គ្រងឯកសារ ទិន្នន័យ ព័ត៌មានរបស់ គ.ជ.ទ.ម.ក
- រាល់ព្រឹត្តិការណ៍ នៅថ្នាក់ជាតិ និងថ្នាក់តំបន់ ដែល គ.ជ.ទ.ម.ក/កម្ពុជា បានរៀបចំ និងចូលរួម ត្រូវបានផ្សព្វផ្សាយតាមបណ្តាញទំនាក់ទំនងសង្គម និងប្រព័ន្ធផ្សព្វផ្សាយ
- បានលើកកម្ពស់ការចែករំលែកព័ត៌មានក្នុងចំណោមអង្គភាពចំណុះ និងមន្ត្រីនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើនការយល់ដឹង និងពង្រឹងកិច្ចសហការ
- បានលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងការចូលរួម ក្នុងដំណើរការរៀបចំ ការអនុវត្តការងារតាមវិស័យ និងផ្នែកក្នុងក្របខណ្ឌការងារ MRC
- បាននិងកំពុងរៀបចំផលិតឃ្លីបវីដេអូ ស្តីពី៖ ១) ទន្លេមេគង្គ ដើម្បីការអភិវឌ្ឍដោយចីរភាព និង ២) សកម្មភាព និងសមិទ្ធផលការងាររយៈពេល ១ឆ្នាំ របស់ គ.ជ.ទ.ម.ក
- រាល់កិច្ចជំនួបពិភាក្សាការងារជាមួយភាគីពាក់ព័ន្ធ, តែងបានផ្តល់ជូន និងចែកផ្សាយនូវឯកសារសំខាន់ៗ រួមមាន ព្រឹត្តប័ត្រព័ត៌មានស្ថាប័ន, ផែនការយុទ្ធសាស្ត្រឆ្នាំ២០២៤-២០២៨, ផែនការចង្អុលថ្នាក់ជាតិឆ្នាំ២០២១-២០២៥, របាយការណ៍សកម្មភាពការងារនិងសមិទ្ធផលប្រចាំឆ្នាំកន្លងមក និងផែនការការងារប្រចាំឆ្នាំ កិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥, នីតិវិធីសម្រាប់ការគ្រប់គ្រងការប្រើប្រាស់ទឹក, យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងឆ្នាំ២០២១-២០៣០, និងឯកសារគោលការណ៍ណែនាំពាក់ព័ន្ធផ្សេងទៀត
- បានផ្សព្វផ្សាយនៅថ្នាក់ជាតិ លើរបាយការណ៍គុណភាពទឹកឆ្នាំ ២០២៣, របាយការណ៍វាយតម្លៃហេតុប៉ះពាល់ បរិស្ថានសម្រាប់ការសាកល្បងអនុវត្តដោយស្ម័គ្រចិត្ត នៃគោលការណ៍វាយតម្លៃហេតុប៉ះពាលបរិស្ថានឆ្លងដែនសម្រាប់គម្រោងទំនប់វារីអគ្គិសនី សេកុង A របស់ឡាវ, ពិធីអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ខួបលើកទី ១១៣ ក្រោមមូលបទ " ស្ត្រី និងក្មេងស្រី ក្នុងបរិវត្តកម្មឌីជីថល"










- បានគាំទ្រដល់ការបង្កើតមជ្ឈមណ្ឌលអប់រំ និងទស្សនា របស់ MRC សម្រាប់ផ្តល់ឱកាសជាសាធារណៈដើម្បីស្វែងយល់

អំពីទន្លេមេគង្គ និងកិច្ចសហប្រតិបត្តិការតំបន់សម្រាប់ការអភិវឌ្ឍដោយចីរភាពក្នុងអាងទន្លេមេគង្គ។ មន្ត្រីកម្ពុជា បានចូលរួមក្នុងពិធីសម្ពោធមជ្ឈមណ្ឌល ដែលបានបើកសម្ពោធដោយឯកឧត្តម Sonexay Siphandone នាយករដ្ឋមន្ត្រីសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ។










## ៤.២ បញ្ហាប្រឈម

ទន្ទឹមនឹងវឌ្ឍនភាព និងសមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានក្នុងឆ្នាំ២០២៤ ដូចបានរៀបរាប់ខាងលើ, គ.ជ.ទ.ម.ក ក៏បានជួបប្រទះនូវភាពប្រឈមមួយចំនួន ដែលធ្វើឱ្យការអនុវត្តការងាររបស់ខ្លួនលើផ្នែកខ្លះ មិនអាចដំណើរការបានដោយរលូន និងមានប្រសិទ្ធភាព។ តែទោះជាយ៉ាងនេះក្តី ក៏ គ.ជ.ទ.ម.ក បានខិតខំប្រឹងប្រែងពុះពារជំនះ ដោយបានអនុវត្តនូវវិធានការជាដំណោះស្រាយ ដើម្បីធានាឱ្យមានប្រសិទ្ធភាពក្នុងការអនុវត្តផែនការការងារ មានដូចក្នុងតារាងខាងក្រោម៖

| បញ្ហាប្រឈម | វិធានការជាដំណោះស្រាយ |
|---|---|
| ការប្រែប្រួលរបបជលសាស្ត្រ និងលំហូរទឹកក្នុងអាងទន្លេមេគង្គ | បានបន្តតាមដាន រាយការណ៍ និងផ្សព្វផ្សាយស្ថានភាពជលសាស្ត្រក្នុងអាងទន្លេមេគង្គក្រោម តាមបណ្តាញផ្សព្វផ្សាយសង្គម និងវិបសាយ |
| តម្រូវការទឹក ស្បៀង និងថាមពល ក្នុងបណ្តាប្រទេសតាមដងទន្លេ បន្តមានការកើនឡើងជាលំដាប់ | បានសហការលើការសិក្សារួមគ្នា និងពង្រឹងប្រសិទ្ធភាពនៃកិច្ចដំណើរបណ្តាញស្ទួលតាមដានទន្លេ |
| យន្តការតំបន់ពាក់ព័ន្ធនឹងមេគង្គ មានច្រើន បាននិងកំពុងដំណើរការក្នុងតំបន់មេគង្គ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងបន្ថែម និងការចូលរួមឱ្យកាន់តែសកម្ម | បានបន្តសហការ ជំរុញ និងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥ |
| សមត្ថភាព និងធនធានគាំទ្រដល់កិច្ចដំណើរការការងារនៅមានកម្រិត | បានរួមសហការ ពង្រឹងការអនុវត្តវិធានគ្រប់គ្រងការប្រើប្រាស់ទឹក គោលការណ៍ណែនាំ និងឧបករណ៍បច្ចេកទេស និងការធ្វើបច្ចុប្បន្នភាពបន្ថែម |

## ៥. ការបូកសរុប និងសេចក្តីសន្និដ្ឋាន

ក្នុងឆ្នាំ២០២៤, គ.ជ.ទ.ម.ក បានអនុវត្តការងារក្នុងផែនការយុទ្ធសាស្ត្ររបស់ខ្លួន និងផែនការយុទ្ធសាស្ត្រ MRC ឆ្នាំ២០២១-២០២៥ ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងគ្រប់កិច្ចការងារ និងសកម្មភាពរបស់ខ្លួនក្នុងក្របខណ្ឌជាតិ ដោយមានកិច្ចសហការជាមួយក្រសួងស្ថាប័នជាសមាជិក និងក្នុងក្របខណ្ឌតំបន់ក្រោមយន្តការ MRC ដែលរួមសហការជាមួយបណ្តាប្រទេសជាសមាជិកដទៃទៀត (ឡាវ ថៃ និងវៀតណាម) និងយន្តការតំបន់និងអន្តរជាតិពាក់ព័ន្ធនានា ធ្វើឱ្យ MRC ដែលស្ថាប័នអន្តររដ្ឋាភិបាលថ្នាក់តំបន់ សម្រេចបាននូវវឌ្ឍនភាព និងសមិទ្ធផលសំខាន់ថ្មីៗជាច្រើនបន្ថែមទៀត ក្នុងការជំរុញ លើកកម្ពស់កិច្ចសហប្រតិបត្តិការ កិច្ចខិតខំប្រឹងប្រែងរួម និងភាពជាដៃគូ សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងអាងទន្លេមេគង្គ។ បណ្តាសកម្មភាពដែលមានលើកឡើងខាងលើ ក៏ពិតបានចូលរួមគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ នៃរាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ ដើម្បីការអភិវឌ្ឍ និងវិបុលភាពផ្នែកសេដ្ឋកិច្ច ប្រកបដោយចីរភាព និងដោយបរិយាបន្នសម្រាប់កម្ពុជា។

សមិទ្ធផលក្នុងក្របខណ្ឌតំបន់ និងដោយឡែកសម្រាប់កម្ពុជា ដែលសម្រេចបានកន្លងមកក្នុងឆ្នាំ២០២៤ គឺបានមកពីកិច្ចសហការ ការគាំទ្រ និងការចូលរួមយ៉ាងសកម្ម និងប្រកបដោយប្រសិទ្ធភាព ពីបណ្តាក្រសួង-ស្ថាប័នជាសមាជិក គ.ជ.ទ.ម.ក អាជ្ញាធរដែនដី និងដៃគូពាក់ព័ន្ធផ្សេងទៀត ព្រមទាំងការយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ មន្ត្រីបុគ្គលិក គ.ជ.ទ.ម.ក ក្នុងការបំពេញតួនាទី ភារកិច្ច ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងប្រកបដោយប្រសិទ្ធភាព។

សមិទ្ធផលសំខាន់ៗដែលសម្រេចបានទាំងនេះ បានបង្ហាញពីភាពជោគជ័យបន្ថែមទៀតរបស់ គ.ជ.ទ.ម.ក ក្នុងការចូលរួមចំណែកជំរុញ និងលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ទឹក ផែនការ និងសកម្មភាពជាអាទិភាពរបស់ MRC ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធប្រកបដោយចីរភាព និងនិរន្តរភាពបរិស្ថានក្នុងអាងទន្លេមេគង្គ។

ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល, គ.ជ.ទ.ម.ក ផ្អែកលើផែនការយុទ្ធសាស្ត្ររបស់ខ្លួនឆ្នាំ ២០២៤-២០២៨ នឹងបន្តខិតខំបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ឱ្យបានកាន់តែសកម្ម និងឱ្យមានប្រសិទ្ធភាពថែមទៀត យកចិត្តទុកដាក់លើការកសាង អភិវឌ្ឍន៍ និងពង្រឹងសមត្ថភាពធនធានមនុស្ស និងស្ថាប័ន កសាង និងពង្រឹងទំនាក់ទំនង កិច្ចសហការ និងភាពជាដៃគូ ឱ្យបានកាន់តែប្រសើរថែមទៀត ជាមួយគ្រប់ភាគី និងដៃគូពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ដើម្បីនាំមកនូវវឌ្ឍនភាព សមិទ្ធផល និងជោគជ័យថ្មីៗបន្ថែមទៀត សម្រាប់ស្ថាប័នខ្លួន និងប្រទេសកម្ពុជា ដើម្បីរួមចំណែក និងចូលរួមក្នុងបេសកកម្ម ឆ្ពោះទៅសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន សម្រាប់កម្ពុជា និងនៅក្នុងតំបន់មេគង្គ។

## ៦. ទិសដៅការងារឆ្នាំ ២០២៥

ដោយក្នុងឆ្នាំ២០២៤ សម្រាប់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៧ នៃរដ្ឋសភាបានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ឆ្នាំ២០២៤-២០២៨ និងដើម្បីចូលរួមចំណែកគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ លើអាទិភាពការងារដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានទឹក និងអាងទន្លេឱ្យមានប្រសិទ្ធភាព និងដើម្បីគាំទ្រ និងពង្រឹងការចូលរួមរបស់កម្ពុជា សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងអាងទន្លេមេគង្គ ទាំងនៅជាតិ និងថ្នាក់តំបន់, គ.ជ.ទ.ម.ក បានធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្របច្ចុប្បន្នរបស់ខ្លួន សម្រាប់រយៈពេល ៥ឆ្នាំ ២០២៤-២០២៨ ដោយក្នុងនោះ បានកំណត់ទិសដៅ និងកិច្ចការជាអាទិភាពចំនួន ៥ ដូចក្នុងរូបបង្ហាញខាងក្រោម៖




ផែនការយុទ្ធសាស្ត្រ ត្រូវអនុវត្តតាមរយៈផែនការការងារដែលត្រូវរៀបចំជារៀងរាល់ឆ្នាំ ដែលសម្រាប់ឆ្នាំ ២០២៥ , គ.ជ.ទ.ម.ក មានទិសដៅការងារសង្ខេបជារួមផ្តោតលើអាទិភាព ដូចខាងក្រោម៖

- បន្តពង្រឹង លើកកម្ពស់សមត្ថភាពធនធានមនុស្ស និងប្រសិទ្ធភាពនៃកិច្ចដំណើរការស្ថាប័ន
- បន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ ឱ្យបានកាន់តែរឹងមាំ និងប្រសើរថែមទៀត ក្នុងកិច្ចខិតខំប្រឹងប្រែង

រួមដើម្បីការគ្រប់គ្រង និងការអភិវឌ្ឍ ប្រកបដោយប្រសិទ្ធភាព និងដោយចីរភាព ក្នុងអាងទន្លេមេគង្គ

- បន្តលើកកម្ពស់ការចូលរួម និងកិច្ចពិគ្រោះយោបល់ជាមួយភាគីសហការពាក់ព័ន្ធ ក្នុងដំណើរការអនុវត្ត រៀបចំ ធ្វើបច្ចុប្បន្នភាព ផែនការយុទ្ធសាស្ត្រ គោលការណ៍ណែនាំ និងឧបករណ៍បច្ចេកទេស ក្នុងការគ្រប់គ្រង ធនធានទឹកចម្រុះ និងអាងទន្លេ
- បន្តពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានប្រតិបត្តិសម្រាប់ការគ្រប់គ្រងការប្រើប្រាស់ទឹក និងអាងទន្លេ ឱ្យបានកាន់តែប្រសើរថែមទៀត
- បន្តសហការក្នុងកិច្ចដំណើរការ និងការធ្វើឱ្យប្រសើរលើការពិនិត្យតាមដានទន្លេ និងស្ថានភាពធនធានធម្មជាតិក្នុងអាង
- បន្តលើកកម្ពស់ការយល់ដឹង ការផ្សព្វផ្សាយ និងការប្រើប្រាស់ផលិតផលសម្រេចតាមវិស័យ និងផ្នែករបស់ MRC ដើម្បីគាំទ្រ និងធ្វើឱ្យប្រសើរដល់ការគ្រប់គ្រង ការប្រើប្រាស់ ការអភិវឌ្ឍ និងការអភិរក្សធនធានទឹក ធនធានពាក់ព័ន្ធ និងអាងទន្លេ
- សហការពិនិត្យតាមដានវឌ្ឍនភាព និងប្រសិទ្ធភាពការងារនៅថ្នាក់ជាតិ និងតំបន់ និងការរៀបចំផែនការការងារបន្ត៕

#576, National Road No 2, Sangkat Chak Angre Krom, Khan Meanchey,

Phnom Penh, Cambodia

Website: http://www.cnmc.gov.kh